រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

ជំណឹងល្អបំផុត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

មេរៀន «ដំណឹងល្អបំផុត» មានអត្ថបទសិក្សាព្រះគម្ពីរខ្លីៗចំនួន៨ សំរាប់បង្រៀនមេគ្រួសារទាំងឡាយ នៅតាមផ្ទះរបស់ពួកគេ ។ គោលបំណងរបស់មេរៀននេះ គឺដឹកនាំមេគ្រួសារ និងក្រុមគ្រួសារ របស់គាត់អោយថ្វាយខ្លួនទៅព្រះគ្រីស្ត និងទទួលពិធីជ្រមុជទឹក ជាមួយគ្នា ។

នៅក្នុងកិច្ចការជំពូក១០ លោកគ័រនេលា្យសបានដឹងខ្លះៗហើយអំពី ដំណើរជីវិតរបស់ព្រះយេស៊ូ ។ ហេតុនេះហើយបានជាអ្នកផ្សាយ ដំណឹងល្អ មិនចាំបាច់ពន្យល់លោកគ័រនេលា្យសយូរ ដើម្បីអោយ លោកបើកចិត្តចំហទទួលព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់លោក ទេ ។ ប៉ុន្តែ ចំពោះអ្នកដែលមិនដែលឮដំណឹងល្អសោះ ជាទូទៅ អ្នកទាំងនោះច្រើនតែត្រូវស្តាប់ការពន្យល់ផ្សព្វផ្សាយពីដំណឹងល្អ ប្រាំពីរ ឬប្រាំបីដង ដើម្បីអោយគេមានឱកាសជឿដោយស្មោះអស់ ពីចិត្ត ។ ហេតុនេះហើយបានជាអត្ថបទសិក្សាមានចំនួនដល់ទៅ ប្រាំបី ។ ប៉ុន្តែ យើងមិនចាំបាច់បង្ហាត់បង្រៀនអត្ថបទទាំងនោះ ទាល់តែអស់ទេ ប្រសិនបើអ្នកសិក្សាបើកចិត្តចំហទទួលដំណឹងល្អ អំពីព្រះយេស៊ូហើយនោះ ។

កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

របៀបប្រើប្រាស់មេរៀន "ដំណឹងល្អបំផុត"

អធិស្ឋានយ៉ាងខ្លាំងក្លា ទូលសូមឱ្យព្រះជាម្ចាស់ដឹកនាំអ្នកឱ្យជួបមេគ្រួសារទាំងឡាយ ដែលកំពុងស្វែងរកសេចក្តីពិត ។ អធិស្ឋានជាពិសេសអោយសាច់ញាតិ និងមិត្តភក្តិរបស់អ្នក ។ តើអ្នកនឹងអធិស្ឋានជាទៀងទាត់ ដើម្បីទូលសូមឱ្យព្រះជាម្ចាស់ណែនាំ និងប្រទានទ្ធានុភាពដល់អ្នក គ្រប់ពេលដែលអ្នកផ្សាយដំណឹងល្អប្រាប់អ្នកដទៃដែរឬទេ ?

© Project WorldReach © SEAN

ហេតុអ្វីក៏អ្នកយកចិត្តទុកដាក់ផ្សព្វផ្សាយដំណឹងល្អខ្លាំងយ៉ាងនេះ ? បើគេចង់អោយព្រះជាម្ចាស់សង្គ្រោះគេ គេនឹងមកព្រះវិហារដោយខ្លួនឯងហើយ ។



កុំគិតអញ្ចឹង ! ព្រះជាម្ចាស់បង្គាប់យើង ឲ្យចេញទៅស្វែងរកមនុស្សជាប ដែលមិនទាន់មានជំនឿ ។ ក្រុមជំនុំដែលស្តាប់បង្គាប់ព្រះជាម្ចាស់ មិនដែលឈប់ផ្សព្វផ្សាយដំណឹងល្អតាមផ្ទះ និងតាមទីកន្លែងសាធារណៈទេ ។

កំណត់ចំណាំ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- និយាយប្រាប់គ្រួសាររបស់អ្នកពីការថ្វាយខ្លួនរបស់លោកប៉ូល ។
- ទទួលពិធីជ្រមុជទឹក ជាមួយអស់អ្នកដែលទទួលជឿក្នុងក្រុមគ្រួសាររបស់អ្នក ។ (បើសិនជាពីមុន អ្នកបានទទួលពិធីជ្រមុជទឹកជាគ្រីស្តជនហើយ តែក្រោយមក ងាកចេញពីព្រះជាម្ចាស់វិញ រួចពេលនេះ អ្នកមានបំណងចង់ដើរតាមព្រះជាម្ចាស់ជាថ្មីទៀតនោះ អ្នកត្រូវលន់តួបាប និង ឈប់ប្រព្រឹត្តអំពើបាបដែលអ្នកធ្លាប់ប្រព្រឹត្ត ចំពោះខ្លួនអ្នកផ្ទាល់ និងអ្នកដទៃ ហើយត្រូវទុកចិត្តថាព្រះជាម្ចាស់ លើកលែងទោសអោយអ្នក) ។ ត្រូវអរព្រះគុណព្រះយេស៊ូ ដែលទ្រង់បានអត់ទោសរាល់អំពើបាបអ្នក ហើយទូលសូមឱ្យព្រះអង្គជួយអ្នកអោយកែប្រែ និងកសាងមេត្រីភាពដែលស្និទ្ធស្នាល និងពេញលេញជាមួយព្រះអង្គ នៅក្នុងជីវិតរបស់អ្នកជាថ្មីទៀត ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

ជាដំបូង បង្រៀនមេគ្រួសារសិន ។ អ្នកអាចជួយមេគ្រួសារទាំងនោះអោយចេះបង្រៀនមេរៀនដល់ប្រពន្ធ និងកូនគាត់ ។ ការធ្វើដូច្នេះ ជួយបង្កើតអ្នកដឹកនាំ តាំងពីដើមដំបូងតែម្តង ។



សូមប្រើរូបភាពនិមួយៗរបស់អត្ថបទសិក្សា «ដំណឹងល្អបំផុត» ដោយសួរសំណួរនេះ «តើអ្នកគិតថារូបនេះជាអ្វី ?» ដើម្បីធ្វើឱ្យអ្នកសិក្សាចាប់អារម្មណ៍ និងយល់ពីមេរៀននោះ ។



- អោយ (ដាក់ជង្វាយ) (ម៉ាថាយ ៦:១៩-២០) ។
- ផ្សាយដំណឹងល្អ (ផ្សព្វផ្សាយដំណឹងល្អដល់មនុស្សរហូតដល់គេប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត) (ម៉ាថាយ ២៨:១៨-២០) ។

ខ សំរាប់ទន្ទេញ

«ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក » ។

(ម៉ាថាយ ២៨:១៨-២០)

លោកសូលទទួលពិធីជ្រមុជទឹក ដើម្បីធ្វើតាមពាក្យរបស់អណា-ញ៉ាស ។ ក្រោយមក គាត់ក៏ចាប់ផ្តើមនាំអ្នកឯទៀតមកថ្វាយខ្លួន និងប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត ។

ព្រះគ្រីស្តបង្គាប់អោយយើងបង្កើតសាវ័ក ដែលប្រតិបត្តិតាមគ្រប់សេចក្តីដែលព្រះអង្គបានបង្គាប់ ។ (សូមសិក្សាសេចក្តីបង្គាប់ទាំងនេះ ដោយទន្ទេញអោយចាំស្មាត់ ។ សូមគួសបន្ទាត់ពីក្រោមសេចក្តីណាដែលអ្នកត្រូវប្រតិបត្តិតាម ឱ្យបានប្រសើរឡើងៗ) ។ សេចក្តីបង្គាប់ខ្លះរបស់ព្រះអង្គសំរាប់សាវ័កព្រះអង្គ គឺ :

- កែប្រែចិត្តគំនិត និងជឿ (ម៉ាកុស ១:១៥) ។
- ទទួលពិធីជ្រមុជទឹក (ម៉ាកុស ១៦:១៦) ។
- ស្រឡាញ់ព្រះអម្ចាស់ និងមនុស្សឯទៀតៗ (ម៉ាថាយ ២២:៣៧-៣៩) ។
- ចូលរួមធ្វើពិធីកាច់នំប៉័ង (លូកា ២២:១៧-២០) ។
- អធិស្ឋាន និងអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាចំណីអាហារខាងព្រលឹងវិញ្ញាណ (ម៉ាថាយ ៤:៤, ៦:៥-១៣)។

រូបភាពនៅក្នុងអត្ថបទសិក្សា "ដំណឹងល្អបំផុត" បង្ហាញអំពី :

១- បណ្តាជននៅក្រៅទ្វេកធំ (កំណើតពិភពលោក ជំពូក ៦-៨) ។

២- ព្រះលោហិតហូរចេញពីព្រះអម្ចាស់យេស៊ូ នៅលើឈើឆ្កាង (លូកា ២៣) ។

៣- ឪពុកអោបក្លួនប្រុសវង្វេង ដែលបានកែប្រែចិត្តគំនិត និងត្រឡប់មកផ្ទះវិញ (លូកា ១៥) ។

៤- ជនជាតិអេត្យូពីចង្អុលទៅរកទឹក (កិច្ចការ ៨) ។

៥- ឆ្នាំគុកលុតជង្គង់នៅមុខលោកប៉ូល និងលោកស៊ីឡាស (កិច្ចការ ១៦) ។

៦- ការរើសនំម៉ាណានៅក្នុងវាលរហោស្ថាន (យ៉ូហាន ៦) ។

៧- ជ្រូកដែលមានខ្មោចចូល នាំគ្នារត់ទៅធ្លាក់ក្នុងសមុទ្រ (ម៉ាថាយ ៨:២៨-៣៤) ។

៨- លោកសូល ដែលឃើញពន្លឺមួយចាំងពីផ្ទៃមេឃមកជុំវិញគាត់ ឮព្រះសូរសៀងរបស់ព្រះអម្ចាស់យេស៊ូ (កិច្ចការ ៩) ។

- បង្រៀនអត្ថបទសិក្សាទាំងអស់នោះដល់មេគ្រួសារ ដោយអោយមេគ្រួសារអានវគ្គព្រះគម្ពីរ ហើយអ្នកសួរសំនួរទៅគាត់ ។ នេះជារបៀបបង្រៀនល្អបំផុត ព្រោះអ្នកនឹងមានឱកាសច្រើន ដើម្បីពន្យល់ដល់អ្នកសិក្សាទាំងនោះ ។

  (បើអ្នកសិក្សាមិនចេះអាន សូមអានអោយគេស្តាប់ រួចសរសេរចំលើយរបស់គេ) ។

- របៀបម្យ៉ាងទៀត គឺអ្នកពន្យល់អត្ថបទសិក្សា ដោយសង្ខេប ហើយទុកអត្ថបទនោះឱ្យមេគ្រួសារ ដើម្បីឱ្យគាត់អាចសិក្សាខ្លួនឯង និងសិក្សារួមជាមួយក្រុមគ្រួសាររបស់គាត់ ។

  ពេលដែលអ្នកទៅជួបគាត់លើកក្រោយ សូមពិនិត្យមើលកិច្ចការដែលគាត់បានធ្វើជាមុនសិន ។ បើសិនជាអ្នកសិក្សារៀនចប់សៀវភៅទី១ហើយ សូមអោយសៀវភៅបន្ទាប់ដល់គាត់ទៀត ។ បើសិនជាគាត់ភ្លេចខ្លឹមសាររបស់មេរៀនដែលរៀនហើយ សូមមើលឡើងវិញជាមួយនឹងគាត់ ។ សូមជួយគាត់អោយអាចឆ្លើយសំនួរបាន ។

នេះជាសេចក្តីដែលសាវ័កប៉ុលរៀបរាប់ពីការថ្វាយខ្លួនរបស់គាត់ ។
តើលោកប៉ុលមានឈ្មោះមួយទៀតថាដូចម្តេច ? ស _____

តើមុនពេលថ្វាយខ្លួន លោកប៉ុលធ្វើអាក្រក់ដូចម្តេចខ្លះ ?

_____

_____

តើភ្នែកគាត់ទៅជាយ៉ាងដូចម្តេច ?

_____

តើអ្នកណាបានអធិស្ឋានអោយភ្នែកគាត់មើលឃើញវិញ ?

_____

នៅចុងបញ្ចប់សេចក្តីរៀបរាប់របស់លោកប៉ុល តើអណាញ៉ាសប្រាប់អោយលោកប៉ុលធ្វើដូចម្តេច ?

_____

_____

© Project WorldReach © SEAN

ដោយខ្ញុំពុំអាចមើលអ្វីឃើញ ព្រោះតែពន្លឺរស្មីដ៏រុងរឿងនោះ អស់អ្នក ដែលនៅជាមួយខ្ញុំ បានដឹកដៃនាំខ្ញុំទៅក្រុងដាម៉ាស ។ នៅក្រុងនោះមានបុរសម្នាក់ឈ្មោះអណានាញ៉ាស ជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ត្រឹមត្រូវតាមវិន័យ ហើយជនជាតិយូដានៅក្រុងដាម៉ាសគោរពរាប់អានគាត់គ្រប់ៗគ្នា ។ គាត់មកឈរជិតខ្ញុំ ហើយពោលថា÷ "*បងសាអ៊ូលអើយ សូមឱ្យបងមើលឃើញវិញចុះ!*" ។

រំពេចនោះ ភ្នែកខ្ញុំក៏ភ្លឺឡើង ហើយខ្ញុំមើលឃើញគាត់ ។ គាត់មានប្រសាសន៍ថា÷ "ព្រះនៃបុព្វបុរសរបស់យើង បានជ្រើសរើសបង ដើម្បីអោយបងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ អោយបងបានឃើញព្រះដ៏សុចរិត និងអោយបងបានឮព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់តែម្តង ។ ដ្បិតបងនឹងធ្វើជាបន្ទាល់របស់ព្រះអង្គនៅមុខមនុស្សទាំងអស់ អំពីហេតុការណ៍ ដែលបងបានឃើញ និងអំពីសេចក្តីដែលបងបានឮ ។ ដូច្នេះ តើបងនៅបង្អែរបង្អង់ដល់កាលណាទៀត សូមក្រោកឡើង ទទួលពិធីជ្រមុជទឹក ហើយអង្វររកព្រះនាមព្រះអង្គទៅ ដើម្បីព្រះអង្គលាងបាបអោយ" » ។

(កិច្ចការ ២២)

- លើកទឹកចិត្តអ្នកសិក្សា អោយពន្យល់រឿងរ៉ាវក្នុងព្រះគម្ពីរប្រាប់ក្រុមគ្រួសាររបស់គាត់ ។ នៅក្នុងមេរៀន « ជំណឹងល្អបំផុត » ពីមេរៀនទីមួយដល់ទីប្រាំបី « កិច្ចការដែលត្រូវអនុវត្ត » ណែនាំមេគ្រួសារអោយពន្យល់រឿងរ៉ាវក្នុងព្រះគម្ពីរប្រាប់ក្រុមគ្រួសាររបស់គាត់ ។ ពេលបង្រៀនមេរៀននិមួយៗចប់ហើយ សូមដាក់កិច្ចការនោះអោយមេគ្រួសារធ្វើខ្លួនឯង (សូមពន្យល់ថា កិច្ចការនេះនឹងនាំអោយគេបានទទួលអត្ថប្រយោជន៍ដ៏ធំសំរាប់ជីវិតរបស់គេ) ។

បើសិនជាឪពុកបង្រៀនដល់ក្រុមគ្រួសាររបស់ខ្លួន នោះសមាជិកក្នុងគ្រួសារ ស្រួលនឹងបើកចិត្តថ្វាយខ្លួនជាមួយគ្នា។ សូមសួរសំនួរទៅគាត់ ដើម្បីជួយគាត់អោយអាចនិយាយរឿងរ៉ាវក្នុងព្រះគម្ពីរប្រាប់ដល់គ្រួសារគាត់បាន ។

ឧទាហរណ៍អំពីសំនួរទាំងនោះ :



- លើកទឹកចិត្តអ្នកសិក្សាអោយអញ្ជើញសាច់ញាតិ និងមិត្តភក្តិផ្សេងៗទៀត អោយមកចូលរួមសិក្សា នៅពេលក្រោយទៀត ពីព្រោះព្រះជាម្ចាស់សព្វព្រះហឫទ័យ អោយមនុស្សទាំងអស់បានទទួលសេចក្តីស្រឡាញ់របស់ព្រះអង្គ ។ បើសិនជាអ្នកសិក្សាមិនអាចអញ្ជើញអោយគេមកចូលរួមបានទេ នោះចូរសុំឈ្មោះ និងអាស័យដ្ឋានរបស់ពួកគេ ហើយទាក់ទងជាមួយពួកគេដោយខ្លួនឯង ។ (ប៉ុន្តែ សូមសួរអ្នកសិក្សាឱ្យអនុញ្ញាតិសិន) ។

ពេលខ្ញុំកំពុងតែធ្វើដំណើរទៅជិតដល់ក្រុងដាម៉ាស ប្រមាណជាថ្ងៃត្រង់ ស្រាប់តែមានពន្លឺមួយដ៏ភ្លឺត្រចះត្រចង់ ចាំងពីផ្ទៃមេឃមកជុំវិញខ្ញុំ ។ ខ្ញុំក៏ដួល ហើយឮសំឡេងមួយពោលមកខ្ញុំថា"*សាអ៊ូលអើយ សាអ៊ូល ! ហេតុដូចម្តេចបានជាអ្នកបៀតបៀនខ្ញុំដូច្នេះ ?* ខ្ញុំបានសួរវិញថា÷ "លោកម្ចាស់អើយ តើលោកជានរណា ?" ។ សំឡេងនោះឆ្លើយមកខ្ញុំថា÷ *"ខ្ញុំជាយេស៊ូ អ្នកស្រុកណាសារ៉ែត ដែលអ្នកកំពុងតែបៀតបៀន"* ។

រីឯអស់អ្នកដែលធ្វើដំណើរជាមួយខ្ញុំ ក៏បានឃើញពន្លឺនោះដែរ តែមិនបានឮព្រះសូរសៀងទេ ។

ខ្ញុំក៏សួរថា÷ "ព្រះអម្ចាស់អើយ តើទូលបង្គំ ត្រូវធ្វើដូចម្តេច ?"។ ព្រះអម្ចាស់មានព្រះបន្ទូលមកខ្ញុំថា÷ *"ចូរក្រោកឡើង ទៅក្រុងដាម៉ាសទៅ នៅទីនោះ គេនឹងប្រាប់អ្នកអំពីកិច្ចការទាំងប៉ុន្មានដែលព្រះជាម្ចាស់បង្គាប់អោយអ្នកធ្វើ"* ។

ការប្រតិបត្តិតាមព្រះយេស៊ូគ្រីស្ត

«បងប្អូន និង ចាស់ទុំទាំងអស់គ្នាអើយ សូមស្តាប់ពាក្យដោះសារបស់ខ្ញុំសិន ! » ។ កាលពួកគេឮលោកប៉ូលមានប្រសាសន៍ជាភាសាហេប្រឺដូច្នេះ គេរឹតតែសៀមសាត់ថែមទៀត ។ លោកប៉ូលមានប្រសាសន៍ថា÷ «ខ្ញុំជាជនជាតិយូដា កើតនៅក្រុងតាសុសក្នុងស្រុកស៊ីលីស៊ី ។ ប៉ុន្តែ ខ្ញុំបានមករស់នៅក្រុងយេរូសាឡឹមនេះតាំងពីកុមារ ហើយខ្ញុំបានទទួលការអប់រំតាមវិន័យនៃបុព្វបុរសរបស់យើងយ៉ាងតឹងរ៉ឹងពីសំណាក់លោកកាម៉ាលីអែល ។ ខ្ញុំបានខ្នះខ្នែងបំរើព្រះជាម្ចាស់ ដូចបងប្អូនទាំងអស់គ្នានៅថៃនេះដែរ ។

ខ្ញុំធ្លាប់បៀតបៀនអស់អ្នក ដែលដើរតាមមាគ៌ារបស់ព្រះអម្ចាស់រហូតដល់សម្លាប់គេ ហើយចាប់ចងមនុស្សប្រុសស្រីយកទៅឃុំឃាំងទៀតផង ។ ដូចមានលោកមហាបូជាចារ្យ និងក្រុមព្រឹទ្ធាចារ្យជាសាក្សីស្រាប់ ។ ខ្ញុំបានទទួលលិខិតពីលោកទាំងនោះយកទៅជូនបងប្អូននៅក្រុងដាម៉ាស ដ្បិតខ្ញុំទៅទីនោះ ដើម្បីចាប់ចងពួកអ្នកដែលដើរតាមមាគ៌ានេះ យកមកធ្វើទោសនៅក្រុងយេរូសាឡឹម ។



អត្ថបទសិក្សា ទី ៨

"ជំណឹងល្អបំផុត"



- ជួយមេគ្រួសារអោយបញ្ជាក់ពីជំនឿលើព្រះគ្រីស្តមួយជំហានម្តងៗ ដូច្នេះ នៅពេលដែលអ្នកទៅលេងគាត់លើកទីមួយជំបូង អ្នកប្រហែលជាគ្រាន់តែធ្វើអោយគាត់យល់ព្រមសិក្សាជាមួយអ្នកសិន ។ ពេលក្រោយ សឹមជំរុញគាត់ឱ្យបង្រៀនអត្ថបទសិក្សាទាំងឡាយដល់ក្រុមគ្រួសារគាត់ ដើម្បីអោយជំនឿរបស់គាត់មានការរីកចំរើនកាន់តែខ្លាំងឡើងៗ ។ ចូរសួរគាត់ថា÷ «តើអ្នកអាចពន្យល់អត្ថបទសិក្សានេះ ប្រាប់កូនៗ ឬប្រពន្ធ ឬមិត្តភក្តិ ឬបងប្អូន...។ល។ របស់អ្នកបានដែរឬទេ ? » ។ នៅក្នុងវគ្គសិក្សានិមួយៗ ជួយមេគ្រួសារអោយអាចបញ្ជាក់ពីតម្លៃនៃការសុគតរបស់ព្រះគ្រីស្ត សំរាប់គាត់ និងគ្រួសារគាត់ (គឺពួកគាត់បានព្រះជាម្ចាស់លើកលែងទោសអស់កល្ប) ហើយនិងតម្លៃនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្តដែរ ។ ការសុគតរបស់ព្រះគ្រីស្តនាំឱ្យយើងទទួលការលើកលែងទោសអំពើបាបយ៉ាងណា ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត ក៏នាំអោយយើងមានជីវិតរស់ជាមួយព្រះអង្គយ៉ាងនោះដែរ ។ ព្រះជាម្ចាស់ប្រទានអោយយើងមានជីវិតថ្មីរួមជាមួយព្រះគ្រីស្ត ដែលជាជីវិតបរិសុទ្ធ និងអស់កល្ប ។

ខ សំរាប់ទន្ទេញ

«ចរិតចាស់របស់យើងបានជាប់ឆ្កាងជាមួយព្រះអង្គរួចហើយ ដើម្បីអោយយើងលែងធ្វើជាខ្ញុំបំរើរបស់បាបតទៅទៀត » ។

(រ៉ូម ៥-៦)

កិច្ចការដែលត្រូវអនុវត្ត

- ទូលសូមព្រះវិញ្ញាណព្រះជាម្ចាស់ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូ អោយយាងមកគង់ក្នុងជីវិតរបស់អ្នក ដើម្បីកែប្រែជីវិតរបស់អ្នក ។

- និយាយប្រាប់គ្រួសារអ្នកអំពីព្រះយេស៊ូ ដែលបានកែប្រែបុរសអ្នកស្រុកកេរ៉ាសា ដែលមានខ្មោចចូល ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

នៅក្នុងលូកា ២៤:៤៥-៤៨ ព្រះអម្ចាស់ប្រកាសប្រាប់ពីផ្នែកសំខាន់ៗនៃដំណឹងល្អ គឺ :

- តម្លៃនៃការសុគតរបស់ព្រះអង្គ ដើម្បីយើង និងគ្រួសាររបស់យើង គឺព្រះជាម្ចាស់អាចលើកលែងទោសអំពើបាបរបស់យើង ។

- តម្លៃនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ គឺយើងអាចមានជីវិតថ្មីបរិសុទ្ធ និងអស់កល្បរួមជាមួយព្រះអង្គ ។

- ចំលើយរបស់យើង ដើម្បីឱ្យបានសង្គ្រោះ គឺកែប្រែចិត្ត និងជឿ ។





- នៅពេលដែលមេគ្រួសារ និងក្រុមគ្រួសារគាត់ត្រៀមខ្លួនដើម្បីថ្វាយខ្លួនទៅព្រះគ្រីស្តហើយ សូមឱ្យពួកគាត់អធិស្ឋានសេចក្តីអធិស្ឋានស្រួលៗតាមអ្នក (ថាតាមមួយឃ្លាម្តងៗ) ។ អធិស្ឋានយឺតៗ ទុកពេលឱ្យពួកគាត់អធិស្ឋានតាមអ្នកបាន ។ ប្រើឃ្លាស្រួលៗ (ឧទាហរណ៍ «សូមលើកលែងទោសអំពើបាបរបស់ខ្ញុំ» «សូមអរព្រះគុណ ដែលព្រះអង្គបានសុគតដើម្បីខ្ញុំ» «សូមព្រះអង្គយាងមកគង់ក្នុងជីវិតខ្ញុំ» ។ល។) ។

តើយើងទទួលអត្ថប្រយោជន៍អ្វី ពីការសុគតរបស់ព្រះយេស៊ូ ?

_____

_____

តើយើងទទួលអត្ថប្រយោជន៍អ្វី ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត ?

_____

_____

តើមនុស្សមានបាប អាចទទួលអត្ថប្រយោជន៍ទាំងពីរនេះបានដោយរបៀបណា ?

ដោយសារជំ _____ ។

តើព្រះជាម្ចាស់ចង់អោយអ្នកកែប្រែដូចម្តេច ?

_____

តើមនុស្សបាបដែលទន់ខ្សោយ អាចកែប្រែឡើងវិញបាន ដោយសារបុទ្ធានុភាពរបស់នរណា ?

_____

តើព្រះគ្រីស្តមានឫទ្ធានុភាពអាចកែប្រែអ្នក និងគ្រួសារអ្នកដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

បុរសអ្នកស្រុកកេរ៉ាសា ដែលព្រះយេស៊ូបានកែប្រែ ចង់ជិះទូកទៅជាមួយព្រះយេស៊ូ តែព្រះអម្ចាស់ចង់អោយគាត់ធ្វើអ្វីផ្សេងវិញ ។

តើព្រះយេស៊ូប្រាប់គាត់អោយធ្វើអ្វី ?

_____

_____

បុរសនោះធ្វើតាមព្រះអម្ចាស់ ហើយនិយាយប្រាប់គ្រួសារគាត់ អំពីអ្វីៗគ្រប់យ៉ាង ដែលព្រះគ្រីស្តបានធ្វើ ។ តើអ្នកបានត្រៀមខ្លួនដើម្បីនិយាយប្រាប់គ្រួសារអ្នក និងមិត្តភក្តិរបស់អ្នក ពីអ្វីៗដែលព្រះគ្រីស្តបានធ្វើសំរាប់អ្នក ហើយឬនៅ ?

☐ ត្រៀមខ្លួនហើយ ។

☐ មិនទាន់ត្រៀមខ្លួនទេ ។



- ពេលអ្នកសួរសំនួរ ដែលមាននៅក្នុងមេរៀនផ្សេងៗ សូមស្តាប់អ្នកសិក្សា និងគោរពមតិយោបល់របស់គាត់ ។ ទោះបីជាគាត់និយាយខុស ក៏មិនត្រូវនិយាយថា÷ «ទេខុសហើយ» តែគ្រាន់តែនិយាយថា÷ «ប្រហែលជាយើងគួរនិយាយថា...» ។
- ជំរុញអោយអ្នកសិក្សានិយាយអំពីសេចក្តីសង្ឃឹម ជម្ងឺ ការភ័យខ្លាច និងបញ្ហារបស់គ្រួសារគាត់ ។ អធិស្ឋានសំរាប់កិច្ចការទាំងនេះ ។

- នាំគ្រីស្តជនម្នាក់ទៀតទៅជាមួយអ្នក ដើម្បីបង្ហាត់បង្រៀនគេអោយចេះផ្សព្វផ្សាយដំណឹងល្អផងដែរ ។ នៅពេលដែលគ្រីស្តជននោះឃើញរបៀបដែលអ្នកបង្រៀនគេ គាត់អាចធ្វើតាមអ្នកបាន ។ សូមអោយគាត់បង្ហាត់បង្រៀនផ្នែកខ្លះនៃការសិក្សា ។ បន្ទាប់មក ចាត់ឱ្យគាត់ទៅផ្សព្វផ្សាយដំណឹងល្អនៅកន្លែងផ្សេងទៀត ដោយនាំគ្រីស្តជនឯទៀតទៅជាមួយផង ។ ពួកសាវ័កចេញទៅពីរៗនាក់ ។ យើងក៏ត្រូវធ្វើតាមគំរូរបស់ពួកគេដែរ ។

- គួរកុំនាំគ្រីស្តជនចាស់ទុំ ទៅធ្វើការសិក្សាជាមួយច្រើនពេក (ក្រៅពីគ្រីស្តជនម្នាក់ដែលអ្នកបង្ហាត់បង្រៀន) ។ បើនាំគ្រីស្តជនចាស់ទុំមកច្រើនពេក អ្នកសិក្សាដែលមិនទាន់ថ្វាយខ្លួន អាចនឹងមានការស្មាក់ស្មើរក្នុងចិត្ត ។ នៅចំពោះមុខគ្រីស្តជនចាស់ទុំច្រើនផ្សេងទៀត គាត់មិនហ៊ានឆ្លើយនឹងសំណួរទេ ។

  កុំចាត់ទុកពួកគេ ដូចជាសមាជិកនៅក្នុងក្រុមជំនុំឡើយ ។ ពួកគេមិនទាន់ក្លាយជាអ្នកជឿទេ បើធ្វើដូចនេះ ពួកគេនឹងមានអារម្មណ៍មិនស្រួលនៅក្នុងចិត្ត ។

តើបុរសក្នុងរឿងនេះ មានបញ្ហាអ្វី ?

_____

_____

ព្រះអម្ចាស់យេស៊ូបញ្ជាអោយពួកខ្មោចចេញពីបុរសនោះ ។ តើពួកខ្មោចទាំងនោះចេញទៅណា ?

_____

តើបន្ទាប់មក សត្វជ្រូកទាំងនោះធ្វើអ្វី ?

_____

តើបន្ទាប់ពីខ្មោចចេញបាត់ទៅ បុរសនោះមានសភាពដូចម្តេច ?

_____

តើព្រះគ្រីស្តមានឫទ្ធានុភាពអាចកែប្រែទាំងមនុស្ស ដែលធ្លាក់ចុះខ្លាំង ដោយសារអំណាចរបស់វិញ្ញាណអាក្រក់ បានដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

គេទូលអង្វរព្រះយេស៊ូ ឱ្យចាកចេញពីស្រុកភូមិរបស់គេ ។ ពេលព្រះអង្គកំពុងយាងចុះទូក បុរសដែលខ្មោចចូលពីមុនបានអង្វរសុំនៅជាមួយព្រះអង្គ ។ ព្រះយេស៊ូមិនយល់ព្រមទេ ផ្ទុយទៅវិញទ្រង់មានព្រះបន្ទូលថា÷ *«ចូរអ្នកត្រឡប់ទៅផ្ទះ ទៅនៅជាមួយក្រុមគ្រួសារវិញចុះ ហើយរៀបរាប់ហេតុការណ៍ទាំងប៉ុន្មាន ដែលព្រះអម្ចាស់បានប្រោសដល់អ្នក ដោយព្រះហឫទ័យអាណិតអាសូរ»* ។

បុរសនោះក៏ចេញទៅ ហើយចាប់ផ្តើមប្រកាសប្រាប់អោយប្រជាជនក្នុងស្រុកដេកាប៉ូល ជឹងអំពីការទាំងអស់ ដែលព្រះយេស៊ូបានប្រោសដល់គាត់ ។ អស់អ្នកដែលបានឮពាក្យគាត់ កោតស្ងប់ស្ងែងក្រៃលែង ។ (ម៉ាកុស ៥:១-២០) ។

តើពួកខ្មោចជឹងអំពីឫទ្ធានុភាពរបស់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដែរឬទេ ?

☐ ជឹង ។

☐ មិនជឹងទេ ។

- បើអ្នកសិក្សាយល់ដំណឹងល្អច្បាស់ ហើយថ្វាយខ្លួនមុនពេលបានរៀនចប់អត្ថបទសិក្សាទាំងអស់ គាត់និងសមាជិកគ្រួសាររបស់គាត់ដែលជឿហើយ អាចទទួលពិធីជ្រមុជទឹកបាន ។ សូមកុំពន្យារពេលធ្វើពិធីជ្រមុជទឹក គ្រាន់តែដើម្បីរៀនអោយចប់អត្ថបទសិក្សាទាំងអស់នោះឡើយ ។

  ប្រសិនបើអ្នកធ្វើការជាមួយនិកាយ ឬសមាគមរបស់ក្រុមជំនុំ សូមធ្វើតាមរបៀបរបបរបស់ពួកគេ សំរាប់ទទួលសមាជិកថ្មីចុះ ។

- បើសិនជានរណាម្នាក់មិនយកចិត្តទុកដាក់ ឬ គ្រាន់តែចង់ជជែកតវ៉ា សូមឈប់បង្រៀនពួកគេចុះ ។ យើងគួរចំណាយពេលវេលា ដើម្បីស្វែងរកមនុស្សដែលយកចិត្តទុកដាក់ចំពោះដំណឹងល្អវិញ ។



- ពេលអ្នកផ្សព្វផ្សាយដំណឹងល្អ សូមធ្វើតាមគំរូរបស់លោកពេត្រុស ។ អាន និងរិះគិតអំពីកិច្ចការ ១០:១-៤៨ ។

□ នៅពេលដែលបានធ្វើកិច្ចការនេះហើយ សូមគូសសញ្ញា «✓» នេះ ក្នុងប្រអប់ «□» ។

ព្រះយេស៊ូមានព្រះបន្ទូលសួរទៅខ្មោចថា÷ «*ឯងឈ្មោះអី ?*» ខ្មោចទូលឆ្លើយថា÷ «*ទូលបង្គំឈ្មោះកងទ័ព ដ្បិតយើងខ្ញុំមានគ្នាច្រើន*» ។ វាទទូចអង្វរ សូមកុំអោយព្រះអង្គបណ្តេញពួកវាចេញពីស្រុកនោះ ។ នៅក្បែរនោះមានជ្រូកមួយហ្វូងធំកំពុងរកស៊ី នៅតាមចង្កេះភ្នំ ។ ពួកខ្មោចអង្វរព្រះយេស៊ូថា÷ « សូមបញ្ជូនយើងខ្ញុំឱ្យទៅចូលក្នុងជ្រូកទាំងនោះទៅ !» ។

ព្រះយេស៊ូក៏យល់ព្រម ។ ខ្មោចចេញពីបុរសនោះទៅចូលក្នុងជ្រូក ។ ហ្វូងជ្រូកដែលមានចំនួនប្រមាណជាពីរពាន់ក្បាល ក៏បោលចុះតាមជំរាលភ្នំ តំរង់ទៅសមុទ្រលង់ទឹកស្លាប់អស់ ។

ពួកអ្នកថែរក្សាហ្វូងជ្រូកយករឿងនេះ រត់ទៅប្រាប់អ្នកនៅទីក្រុង និងអ្នកនៅស្រុកស្រែ មនុស្សម្នាក៏នាំគ្នាមកមើលហេតុការណ៍នោះ ។ គេចូលមករកព្រះយេស៊ូ ឃើញបុរសដែលមានខ្មោចកងទ័ពចូលកាលពីមុន អង្គុយមានសម្លៀកបំពាក់ ហើយដឹងស្មារតី នោះគេក៏នាំគ្នាកោតស្ញប់ស្ញែង ។ អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែករៀបរាប់ប្រាប់គេអំពីហេតុការណ៍ ដែលកើតមានដល់បុរសនោះ និងអំពីហ្វូងជ្រូក ។

ព្រះយេស៊ូគ្រីស្តបំផ្លាស់បំប្រែមនុស្សម្នាក់

ព្រះយេស៊ូ និងពួកសាវ័កបានទៅដល់ត្រើយម្ខាង ក្នុងតំបន់កេ-រ៉ាសា ។ កាលព្រះអង្គយាងឡើងពីទូកភ្លាម មានបុរសម្នាក់ខ្មោចចូលបានចេញពីទីបញ្ចុះសព ដើរតំរង់មករកព្រះអង្គ ។ បុរសនេះស្នាក់នៅតែតាមទីបញ្ចុះសព គ្មាននរណាអាចចងគាត់បានឡើយ សូម្បីតែយកច្រវាក់មកចងក៏មិនជាប់ដែរ ។ គេបានដាក់ខ្នោះជើង និងយកច្រវាក់ចងគាត់ច្រើនដង ប៉ុន្តែ គាត់នៅតែកាច់បំបាក់ច្រវាក់ និងខ្នោះទាំងនោះជានិច្ច ។ គ្មាននរណាអាចបង្ក្រាបគាត់បានឡើយ ។ គាត់រស់នៅតាមទីបញ្ចុះសព និងតាមភ្នំ ទាំងយប់ទាំងថ្ងៃ ហើយចេះតែស្រែក ព្រមទាំងយកថ្មមកអារសាច់ខ្លួនឯងថែមទៀតផង ។

កាលគាត់ឃើញព្រះយេស៊ូពីចម្ងាយ ក៏រត់មកក្រាបថ្វាយបង្គំព្រះ-អង្គ ហើយស្រែកយ៉ាងខ្លាំងថា៖ «ឱ ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ ? ទូលបង្គំអង្វរព្រះអង្គក្នុងព្រះនាមព្រះជាម្ចាស់ សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំអី ! » ។ ខ្មោចនិយាយដូច្នេះ ព្រោះព្រះយេស៊ូបានបញ្ជាវាថា៖ *«នែខ្មោចបិសាច ចូរចេញពីអ្នកនេះទៅ ! »* ។

ការប្រឡង (សំឆ្នូរសង្ខេបមេរៀន)

១- ដើម្បីអាចទទួលបានការជីកនាំ និងឫទ្ធានុភាពរបស់ព្រះជា-ម្ចាស់សំរាប់ផ្សព្វផ្សាយដំណឹងល្អ យើងត្រូវ :

- ☐ អធិស្ឋានដោយជំនឿ អស់ពីចិត្ត ។
- ☐ ពឹងផ្អែកលើចំណេះដឹងរបស់ខ្លួន ។

២- នៅពេលដែលយើងបានទទួលការជីកនាំ និងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដោយសារការអធិស្ឋានហើយ នោះយើងគួរចាប់ផ្តើមផ្សព្វផ្សាយដំណឹងល្អប្រាប់ :

- ☐ ស្ត្រីនិងក្មេងៗ ពីព្រោះពួកគេចាប់អារម្មណ៍ច្រើនជាង ។
- ☐ គ្រួសារទាំងមូល តាមរយៈមេគ្រួសារ ។

៣- យើងចាប់ផ្តើមបង្រៀនមេគ្រួសារសិន ។ ពេលក្រោយមេគ្រួសារទាំងនោះ អាចបង្រៀនក្រុមគ្រួសាររបស់គាត់រៀងៗខ្លួនបាន ។ មធ្យោបាយនេះធ្វើអោយក្រុមគ្រួសារអាចថ្វាយខ្លួនទាំងអស់រួមជាមួយគ្នាបាន ។ ក្រុមជំនុំដែលមានសមាជិកគ្រួសារទាំងមូលៗថ្វាយខ្លួនទាំងអស់គ្នា ជាក្រុមជំនុំដែល :

☐ រឹងមាំ ។

☐ ទន់ខ្សោយ ។

៤- ក្រុមជំនុំដែលរឹងមាំ មានក្រុមគ្រួសារជាច្រើនដែលសមាជិកគ្រួសារទាំងអស់ថ្វាយខ្លួនព្រមគ្នា ។ ក្រុមជំនុំដូចនេះ យកចិត្តទុកដាក់នាំដំណឹងល្អអំពីការសង្គ្រោះ ទៅប្រាប់មនុស្សគ្រប់ៗគ្នា ។ ក្នុងចំណោមឃ្លាទាំងឡាយខាងក្រោមនេះ សូមគូសសញ្ញា «✓» នេះ នៅក្នុងប្រអប់ «☐» ក្បែរឃ្លាដែលជាផ្នែកនៃដំណឹងល្អ ដែលយើងត្រូវប្រកាស :

☐ ព្រះអម្ចាស់យេស៊ូសុគត ដើម្បីលើកលែងទោសអំពើបាបរបស់យើង ។

☐ ព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ដើម្បីប្រទានជីវិតបរិសុទ្ធ និងអស់កល្បដល់យើង ក្នុងអង្គព្រះគ្រីស្ត ។

☐ យើងអាចកែប្រែចិត្ត និងជឿលើព្រះអម្ចាស់ ដើម្បីឱ្យបានទទួលការលើកលែងទោស អោយរួចពីអំពើបាប និងមានជីវិតអស់កល្ប ។

អត្ថបទសិក្សា ទី ៧

"ដំណឹងល្អបំផុត"



© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ទទួលព្រះយេស៊ូគ្រីស្តដែលជានំបុ័ង (អាហារ) ដែលមានជីវិតក្នុងចិត្តអ្នក ដោយមានជំនឿ ។
- ពន្យល់រឿងអំពីនំបុ័ង (អាហារ)ដែលផ្តល់ជីវិតប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

៥- នៅពេលដែលមនុស្សយល់អំពីតម្លៃរបស់ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់ ហើយត្រៀមខ្លួនស្រេចហើយនោះ ពួកគេត្រូវតែ :

- ☐ កែប្រែចិត្តគំនិត និងទទួលពិធីជ្រមុជទឹក ដោយសារមានជំនឿលើព្រះអម្ចាស់យេស៊ូ ។
- ☐ សិក្សាមេរៀនសំរាប់ប្រាំមួយខែអំពីគោលលទ្ធិ មុននឹងទទួលពិធីជ្រមុជទឹក ។

៦- ពួកសាវ័កចេញទៅផ្សព្វផ្សាយដំណឹងល្អ :

- ☐ តែម្នាក់ឯង ។
- ☐ ពីរៗនាក់ ។

នៅពេលដែលយើងផ្សព្វផ្សាយដំណឹងល្អ យើងនាំអ្នកឯទៀតទៅជាមួយផង ។ ធ្វើដូចនេះ គឺយើងបង្ហាត់បង្រៀនអោយគេកាន់តែចេះផ្សព្វផ្សាយដំណឹងល្អថែមទៀត ។

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំអ្នក និងប្រទានឫទ្ធានុភាពដល់អ្នក ដើម្បីអោយអ្នកចេះផ្សព្វផ្សាយដំណឹងល្អ ព្រមទាំងអធិស្ឋានទូលសូមឱ្យសាច់ញាតិ មិត្តភក្តិរបស់អ្នក និងមេគ្រួសារផ្សេងៗទៀតបានទទួលស្គាល់ព្រះ-អម្ចាស់ផងដែរ ។
- ទៅសួរសុខទុក្ខ និងផ្សព្វផ្សាយដំណឹងល្អប្រាប់មេគ្រួសារទាំងឡាយ (ដោយចាប់ផ្តើមពីសាច់ញាតិ និងមិត្តភក្តិរបស់អ្នកផ្ទាល់) ដោយប្រើមេរៀន «ដំណឹងល្អបំផុត» ។
- អធិស្ឋានសំរាប់អ្នកជម្ងឺ ពេលអ្នកទៅសួរសុខទុក្ខតាមផ្ទះ ។
- នាំសមាជិកក្រុមជំនុំឯទៀតទៅជាមួយអ្នក ដើម្បីបង្ហាញពីរបៀបផ្សព្វផ្សាយដំណឹងល្អ ។
- បើសិនជាប្រើមេរៀន «ដំណឹងល្អបំផុត» មិនបានផលទេ សូមសាកល្បងប្រើវិធីផ្សព្វផ្សាយដំណឹងល្អផ្សេងទៀត ។
- កត់ត្រាការរីកចំរើនរបស់ពួកអ្នក ដែលសិក្សាមេរៀនដំណឹងល្អ ដោយប្រើប្រាស់បញ្ជីកត់ត្រានៅទំព័របន្ទាប់នេះ ។

តើជីវិតដែលយើងទទួល ដោយសារព្រះគ្រីស្តមានរយៈពេលប៉ុន្មាន ?

តើយើងទទួលជីវិតថ្មី ដោយសារព្រះវិញ្ញាណរបស់ព្រះជាម្ចាស់តាមរយៈជំនឿលើនរណា ?

តើអ្នក និង គ្រួសារអ្នកចង់ទទួលព្រះអម្ចាស់យេស៊ូក្នុងជីវិត ដែរឬទេ ?

☐ ចង់ ។

☐ មិនចង់ទេ ។

ខ សំរាប់ទន្ទេញ

«ខ្ញុំនេះហើយជាអាហារ ដែលមានជីវិតចុះមកពីស្ថានបរមសុខ ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច » ។

(យ៉ូហាន ៦:៥១)

© Project WorldReach © SEAN

ក្រោយពីពេលដែលព្រះយេស៊ូយកនំប៉័ង និងត្រីតូចៗមកចំអែត
មនុស្ស៥000នាក់នោះមក មនុស្សជាច្រើនដែលដើរតាមព្រះយេស៊ូ
គឺដើរតាមព្រះអង្គ តែដើម្បីអ្វីៗ ដែលពួកគេចង់បានប៉ុណ្ណោះ ។
តើពួកគេចង់បានអ្វីពីព្រះគ្រីស្ត ?

ព្រះយេស៊ូពន្យល់ពួកគេថា ព្រះអង្គផ្តាល់ជានំប៉័ង (ចំណីអាហារ)
ដែលផ្តល់ជីវិត ។ ព្រះអង្គមានបន្ទូលដូចនេះ មិនមែនបានន័យ
ថា យើងអាចទទួលទានសាច់ព្រះអង្គនោះទេ ។ តាមពិតព្រះអង្គ
ចង់មានព្រះបន្ទូលអំពីការទទួលព្រះវិញ្ញាណរបស់ព្រះអង្គ ដោយ
សារជំនឿ ។

យើងទទួលនំប៉័ងជីវិតក្នុងចិត្តយើង តាមរយៈជំនឿ ។ តើនរណា
ជានំប៉័ង (ចំណីអាហារ) ដែលផ្តល់ជីវិត ?

បញ្ជីកត់ត្រាការរីកចំរើនរបស់អ្នកសិក្សាមេរៀន "ដំណឹងល្អបំផុត"

គួររង្វង់ជុំវិញលេខរបស់អត្ថបទសិក្សា ដែលអ្នកសិក្សាម្នាក់ៗ បាន
ទទួល ហើយគួរខ្វែងលេខអត្ថបទ ដែលគេបានសិក្សាចប់សព្វគ្រប់
ហើយ (បន្ទាត់ទីមួយ ជាឧទាហរណ៍) ។

ឈ្មោះអ្នកសិក្សា :

ធីដា	~~១~~ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨
_____	១ ២ ៣ ៤ ៥ ៦ ៧ ៨

© Project WorldReach © SEAN

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

_____ ១ ២ ៣ ៤ ៥ ៦ ៧ ៨

ព្រះអង្គមានព្រះបន្ទូលទៅគេថា÷ «*តើពាក្យទាំងនេះ នាំអោយអ្នករាល់គ្នារវាតចិត្ត បាត់ជំនឿឬ ? ។ មានតែព្រះវិញ្ញាណទេ ដែលផ្តល់ជីវិត និស្ស័យលោកីយ៍មិនអាចផ្តល់ជីវិតបានឡើយ ។ រីឯពាក្យទាំងប៉ុន្មាន ដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណ ដែលផ្តល់ជីវិត* » ។

ចាប់ពីពេលនោះមក ក្នុងចំណោមសាវ័ក មានមនុស្សជាច្រើនដកខ្លួនថយ... ។ ព្រះយេស៊ូក៏មានព្រះបន្ទូលសួរសាវ័កទាំងដប់ពីរូបថា÷« *ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាចង់ចេញទៅដែរឬទេ ?*»។

លោកស៊ីម៉ូនពេត្រុស / សិលាទូលព្រះអង្គថា÷ « បពិត្រព្រះអម្ចាស់ តើអោយយើងខ្ញុំទៅរកនរណាវិញ ? ។ ព្រះបន្ទូលរបស់ព្រះអង្គផ្តល់ជីវិតអស់កល្បជានិច្ច ។ យើងខ្ញុំជឿ ហើយដឹងថា ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ ដែលព្រះជាម្ចាស់ចាត់អោយមក » ។
(យ៉ូហាន ៦) ។

តើព្រះយេស៊ូយកនំប៉័ង និងត្រីតូចៗពីរកន្ទុយនោះមកចំអែតមនុស្សប្រុសបានប៉ុន្មាននាក់ ?

អត្ថបទសិក្សា ទី ១

"ដំណឹងល្អបំផុត"



ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ *«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នាមិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នាគ្មានជីវិតក្នុងខ្លួនឡើយ ។ អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយខ្ញុំក៏នឹងប្រោសគេអោយមានជីវិតរស់ឡើងវិញ នៅថ្ងៃចុងក្រោយបំផុតផង ។ សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំក៏ជាភេសជ្ជៈដ៏ពិតប្រាកដដែរ ។ អ្នកណាពិសាសាច់ និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិតនៅក្នុងអ្នកនោះដែរ ។ អាហារដែលបានចុះពីស្ថានបរមសុខមកមានប្រសិទ្ធិភាពខុសពីអាហារ ដែលបុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគ ជ្បិតលោកទទួលមរណភាពអស់ទៅហើយ ។ រីឯអ្នកដែលបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច »* ។

ក្រោយពីបានស្តាប់ព្រះបន្ទូលរបស់ព្រះអង្គហើយ ក្នុងចំណោមសាវ័ក មានមនុស្សជាច្រើនពោលថា÷« ពាក្យទាំងនេះទាស់ត្រចៀកណាស់ តើនរណាអាចទ្រាំស្តាប់បាន ?» ។

គ្រោះថ្នាក់ខាងព្រលឹងវិញ្ញាណ ដែលយើងអាចជួបប្រទះ

នេះជាដំណើររឿងអំពីក្រុមគ្រួសារលោកណូអេ ។ លោកណូអេជាមនុស្សសុចរិតទៀងត្រង់ នៅក្នុងចំណោមអស់អ្នកដែលរស់នៅជំនាន់លោក ។ លោកបានដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ ។

ព្រះជាម្ចាស់ទតឃើញថា ផែនដីអាក្រក់ខូចអស់ ដ្បិតមនុស្សលោកទាំងប៉ុន្មាននៅលើផែនដី សុទ្ធតែមានកិរិយាមារយាទខិលខូចអាក្រក់ ។ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលមកកាន់លោកណូអេថា÷ *«យើងបានសំរេចចិត្តផ្តាច់ជីវិតសត្វលោកទាំងអស់ ដ្បិតមនុស្សបានធ្វើឱ្យផែនដីពោរពេញដោយអំពើឃោរឃៅ ។ ដូច្នេះ យើងនឹងលុបបំបាត់គេអោយវិនាសសូន្យទៅជាមួយផែនដី »* ។

ព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកណូអេថា÷ *«ចូរអ្នកយកស្រឡៅមកធ្វើទូកមួយយ៉ាងធំ ហើយចែកទូកធំនេះជាច្រើនបន្ទប់ ព្រមទាំងយកជ័រមកលាបភ្ជិតទាំងក្នុង ទាំងក្រៅផង... ។ រីឯយើងវិញ យើងនឹងធ្វើអោយទឹកជន់លិចផែនដី ដើម្បីបំផ្លាញសត្វលោកទាំងអស់ ដែលមានជង្ហើមជីវិតនៅក្រោមមេឃ ។ អ្វីៗទាំងអស់នៅលើផែនដីនឹងត្រូវវិនាសសូន្យ ប៉ុន្តែ យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក »* ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ *«ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា... អាហារដែលព្រះជាម្ចាស់ប្រទានអោយនោះ គឺអ្នកដែលចុះពីស្ថានបរមសុខមក ហើយផ្តល់ជីវិតឱ្យមនុស្សលោក »*។ គេនាំគ្នាទូលព្រះអង្គថា÷ *«លោកម្ចាស់អើយ ! សូមលោកប្រទានអាហារនោះអោយយើងខ្ញុំរហូតតទៅ »* ។

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«ខ្ញុំនេះហើយជាអាហារ ដែលផ្តល់ជីវិត ។ អ្នកណាមករកខ្ញុំ លែងឃ្លានទៀតហើយ អ្នកណាជឿលើខ្ញុំ ក៏លែងស្រេកទៀតដែរ.....»* ។ ជនជាតិយូដារអ៊ូរទាំពីព្រះយេស៊ូ ។ គេពោលថា÷ «អ្នកនេះ ឈ្មោះយេស៊ូជាកូនរបស់លោកយ៉ូសែបទេតើ ! ។ ម្តេចក៏គាត់ពោលថា គាត់ចុះមកពីស្ថានបរមសុខដូច្នេះ ? » ។

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«អាហារដែលខ្ញុំនឹងអោយនោះ គឺខ្លួនខ្ញុំផ្ទាល់ ដែលត្រូវបូជាសំរាប់ឱ្យមនុស្សលោកមានជីវិត »* ។ ជនជាតិយូដាទាស់ទែងគ្នាយ៉ាងខ្លាំង ហើយគេនិយាយថា÷ «តើអ្នកនេះអាចអោយខ្លួនគាត់មកយើងបរិភោគដូចម្តេចកើត ? » ។

© Project WorldReach © SEAN

ព្រះយេស៊ូជ្រាបថា គេបំរុងនឹងចាប់ព្រះអង្គ យកទៅតែងតាំងជាស្តេច ដូច្នេះ ព្រះអង្គក៏យាងចាកចេញពីគេឡើងទៅលើភ្នំសាជាថ្មី តែមួយព្រះអង្គឯង ។

បណ្តាជនបានជួបព្រះអង្គ ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា÷ *«អ្នករាល់គ្នាតាមរកខ្ញុំ មិនមែនមកពីអ្នករាល់គ្នាបានឃើញទីសំគាល់ទេ គឺមកពីអ្នករាល់គ្នាបានបរិភោគអាហារឆ្អែតតែប៉ុណ្ណោះ ។ កុំធ្វើកិច្ចការ ដើម្បីអោយគ្រាន់តែបានអាហារដែលតែងរលួយខូចនោះឡើយ គឺអោយបានអាហារ ដែលនៅស្ថិតស្ថេរ និងផ្តល់ជីវិតអស់កល្បជានិច្ចវិញ »* ។

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«កិច្ចការរបស់ព្រះជាម្ចាស់ គឺអោយអ្នករាល់គ្នាជឿលើអ្នក ដែលព្រះអង្គបានចាត់អោយមក »* ។

គេទូលសួរព្រះអង្គទៀតថា÷ «តើលោកធ្វើការអ្វីជាទីសំគាល់អោយយើងខ្ញុំឃើញ និងជឿលោក ? បុព្វបុរសរបស់យើងបានបរិភោគនំម៉ាណានៅវាលរហោស្ថាន ដូចមានសេចក្តីចែងទុកក្នុងគម្ពីរថា "ព្រះអង្គបានប្រទានឱ្យគេបរិភោគនំប៉័ង ដែលធ្លាក់ពីស្ថានបរមសុខមក" » ។

«អ្នកនឹងចូលទៅក្នុងទូកធំជាមួយកូនប្រុសទាំងបី ប្រពន្ធ និងកូនប្រសារស្រីរបស់អ្នក ។ អ្នកក៏ត្រូវនាំយកសត្វមួយគូៗពីបណ្តាសត្វទាំងអស់ចូលទៅក្នុងទូកធំ ដើម្បីអោយវាបានរួចជីវិត រួមជាមួយអ្នកដែរ គឺត្រូវយកឈ្មោលមួយ ញីមួយ ។ សត្វមួយគូៗក្នុងពូជនីមួយៗនឹងនាំគ្នាមករកអ្នក ដើម្បីអោយបានរួចជីវិត គឺមានសត្វស្លាប សត្វស្រុក សត្វលូនវារនៅលើដី ។ អ្នកក៏ត្រូវយកគ្រឿងបរិភោគទាំងប៉ុន្មាន ទុកជាស្បៀងអាហារសំរាប់បរិភោគ និងទុកជាចំណីសំរាប់សត្វដែរ » ។

លោកណូអេក៏ធ្វើដូច្នោះមែន គឺលោកធ្វើសព្វគ្រប់ទាំងអស់ដូចព្រះជាម្ចាស់បានបង្គាប់ ។ ព្រះអម្ចាស់មានបន្ទូលមកកាន់លោកណូអេថា÷ *«ចូរអ្នកចូលទៅក្នុងទូកធំជាមួយក្រុមគ្រួសារទាំងមូលរបស់អ្នកទៅ ដ្បិតយើងបានឃើញថា ក្នុងចំណោមមនុស្សជំនាន់នេះមានតែអ្នកទេ ដែលសុចរិត....។ ដ្បិតប្រាំពីរថ្ងៃទៀត យើងនឹងធ្វើអោយភ្លៀងបង្អុរចុះមកលើផែនដី ក្នុងរយៈពេលសែសិបថ្ងៃសែសិបយប់ ហើយយើងនឹងលុបបំបាត់សត្វលោកទាំងប៉ុន្មានដែលយើងបានបង្កើតមកអោយអស់ពីផែនដី »* ។

© Project WorldReach © SEAN

លោកណូអេបានធ្វើតាមសព្វគ្រប់ទាំងអស់ ដូចព្រះអម្ចាស់បង្គាប់។ ប្រាំពីរថ្ងៃក្រោយមក ទឹកជំនន់ធំក៏ជន់ឡើងលិចផែនដី ។ សត្វមានជីវិតទាំងប៉ុន្មាន នាំគ្នាទាំងគូៗ មករកលោកណូអេនៅក្នុងទូកធំ គឺមានសត្វទាំងឈ្មោល ទាំងញីពីគ្រប់ពូជ ចូលមកក្នុងទូកធំ ដូចព្រះជាម្ចាស់បានបង្គាប់មកលោកណូអេរួចហើយ ព្រះអម្ចាស់ក៏បិទទ្វារទូកនោះទៅ ។

ទឹកជំនន់ធំបានលិចផែនដីអស់ពេលរយៈពេលសែសិបថ្ងៃ ។ ទឹកបានជន់ឡើង ហើយលើកទូកធំអោយអណ្តែតឡើងផុតពីដី ។ ទឹកជន់កាន់តែខ្លាំងឡើងៗ កំពស់ទឹកកើនឡើងយ៉ាងខ្ពស់ ហើយទូកធំនៅអណ្តែតពីលើផ្ទៃទឹក ។ ទឹកជន់លិចភ្នំទាំងឡាយ ហើយឡើងហួសភ្នំទាំងនោះដប់ប្រាំហត្ថ ។

សត្វលោកទាំងឡាយដែលរស់នៅលើផែនដី ក៏វិនាសសូន្យអស់ទៅ គឺទាំងបក្សាបក្សី សត្វស្រុកសត្វព្រៃ និងសត្វទាំងប៉ុន្មាន ដែលនៅរវើករវាំណ្ឌ ពាសពេញលើផែនដី និងមនុស្សលោកទាំងអស់ដែរ។ អ្វីៗទាំងអស់ដែលមានជង្ហើមជីវិត និងរស់នៅលើដីគោក ក៏ស្លាប់អស់ទៅ...។ នៅសល់តែលោកណូអេ និងអស់អ្នកដែលស្ថិតនៅក្នុងទូកធំជាមួយលោកប៉ុណ្ណោះ ។ (កំណើតពិភពលោក ៦:៩ ដល់ ៧:២៤) ។

អាហារដែលផ្តល់ជីវិតអស់កល្បជានិច្ច

បន្ទាប់មក ព្រះយេស៊ូយាងទៅត្រើយខាងនាយសមុទ្រកាលីឡេ ។ ព្រះយេស៊ូទតឃើញបណ្តាជន មកតាមព្រះអង្គច្រើនកុះករយ៉ាងនេះ ទ្រង់មានព្រះបន្ទូលទៅលោកភីលីពថា÷ «*តើយើងទៅរកទិញអាហារឯណា មកចែកអោយអ្នកទាំងនេះ បរិភោគបាន ?* » ។ លោកភីលីពទូលថា÷ «ទោះបីយើងយកប្រាក់ពីររយដួង ទៅទិញនំបុ័ង ក៏មិនគ្រាន់ដែរ សូម្បីតែម្នាក់មួយដុំតូចៗក៏មិនបានផង »។

មានសាវ័កម្នាក់ឈ្មោះអន់ដ្រេ ទូលទៅព្រះអង្គថា÷ «នៅទីនេះក្មេងប្រុសម្នាក់មាននំបុ័ងប្រាំដុំ និងត្រីតូចៗពីរកន្ទុយ ។ ប៉ុន្តែ បើមានតែប៉ុណ្ណឹង ធ្វើម្តេចនឹងអោយគ្រាន់សំរាប់មនុស្សដ៏ច្រើនយ៉ាងនេះ ?» ។ ព្រះយេស៊ូមានព្រះបន្ទូលថា÷ «*សុំឱ្យគេអង្គុយចុះ* »។ នៅទីនោះមានស្មៅច្រើន បណ្តាជនក៏នាំគ្នាអង្គុយ ។ មានមនុស្សប្រុសទាំងអស់ប្រមាណប្រាំពាន់នាក់ ។

ព្រះយេស៊ូយកនំបុ័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានអោយអ្នកអង្គុយនៅទីនោះ ។ រីឯត្រីវិញ ព្រះអង្គក៏ធ្វើដូច្នោះដែរ ទ្រង់ប្រទានអោយគេតាមតែម្នាក់ៗចង់បាន ។

អត្ថបទសិក្សា ទី ៦

"ដំណឹងល្អបំផុត"



ឥឡូវនេះ សូមសរសេរចំលើយរបស់អ្នកចំពោះសំនួរទាំងនេះ :

ហេតុអ្វីបានជាព្រះជាម្ចាស់សង្គ្រោះលោកណូអេ ?

ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់ទោសពិភពលោក កាលពីសម័យដើមយូរលង់នោះ ?

សព្វថ្ងៃនេះ ក៏ព្រះជាម្ចាស់ទតមើលមកផែនដីដែរ ។ តើអ្នកគិតថាព្រះអង្គគិតយ៉ាងណាអំពីពិភពលោកសព្វថ្ងៃនេះ ? តើព្រះអង្គសប្បាយព្រះទ័យ ឬនឹកស្តាយពិភពលោកសព្វថ្ងៃនេះ ?

សូមគូសបន្ទាត់ពីក្រោមសេចក្តីដែលជាលទ្ធផលនៃអំពើបាប :

សង្គ្រាម **ឧក្រិដ្ឋកម្ម** **ការបែកបាក់គ្រួសារ**

ទុក្ខព្រួយ **ភាពក្រខ្សត់** **ការជំនុំជំរះអស់លក្ប**

ការភ្ញាក់ផ្អើល **សេចក្តីស្លាប់**

យោងទៅតាមព្រះបន្ទូលព្រះជាម្ចាស់ សេចក្តីទាំងនេះជាលទ្ធផលនៃអំពើបាប ។

រឿងពីសម័យបុរាណអំពីទូក ដែលបានសង្គ្រោះមនុស្សប្រាំបីនាក់អោយរួចពីទឹកជំនន់ ធ្វើអោយយើងនឹកឃើញពីព្រឹត្តិការណ៍មួយទៀត ដែលមានសារៈសំខាន់ខ្លាំងជាង សំរាប់ពេលសព្វថ្ងៃនេះ ។ ព្រះគម្ពីរចែងថា ព្រះយេស៊ូគ្រីស្តបានសុគត ដើម្បីធ្វើជាយញ្ញបូជាលោះបាបរបស់យើង ។ ព្រះអង្គជា «ទូក» ដែលសង្គ្រោះយើងពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។

តើយើងនឹងមានគ្រោះថ្នាក់ដូចម្តេច បើសិនជាយើងមិនបានព្រះ-ជាម្ចាស់លើកលែងទោសអំពើបាប ដោយសារព្រះយេស៊ូគ្រីស្តទេ?

កិច្ចការដែលត្រូវអនុវត្ត

- ទូលសូមឱ្យព្រះជាម្ចាស់ ប្រទានការសង្គ្រោះដ៏នៅអស់កល្ប តាមរយៈព្រះយេស៊ូដល់អ្នក (ការនេះមិនមែនកើតមានដោយសារអំពើល្អ ដែលអ្នកបានធ្វើនោះទេ តែដោយសារតែអ្វីៗ ដែលព្រះគ្រីស្តបានធ្វើ ដោយសុគត ដើម្បីយើង និងមានព្រះជន្មរស់ឡើងវិញ) ។
- ពន្យល់រឿងអំពីឆ្នាំគុកប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

តើអ្នកជឿថា ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត អាចផ្តល់ជីវិតថ្មីដល់អ្នក និងគ្រួសាររបស់អ្នកដែរឬទេ ?

☐ អាចផ្តល់ជីវិតថ្មី ។

☐ មិនអាចផ្តល់ជីវិតថ្មីទេ ។

ព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ចង់ប្រទានជីវិតថ្មីដល់អ្នក ។ តើជីវិតថ្មីនេះ មានរយៈពេលប៉ុន្មាន ?

ខ សំរាប់ទន្ទេញ

«អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿ នឹងត្រូវទទួលទោស » ។

(ម៉ាកុស ១៦:១៦)

តើព្រះយេស៊ូនៅសុគតរហូតឬ ?

តើមានការអ្វីកើតឡើងនៅថ្ងៃទីបី ?

ខ សំរាប់ទន្ទេញ

«ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធរួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង »។ (១ យ៉ូហាន ១:៩)

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានលន់តួសារភាពអំពើបាបរបស់អ្នកទៅព្រះជាម្ចាស់។
- និទានរឿងទឹកជំនន់ប្រាប់គ្រួសារអ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

អត្ថបទសិក្សា ទី ២

"ដំណឹងល្អបំផុត"



តើលោកប៉ូល និងលោកស៊ីឡាសប្រាប់ឆ្នាំគុកថា ត្រូវធ្វើអ្វី ដើម្បីអោយបានសង្គ្រោះ ?

ក្រោយដែលបានលាងស្នាមរបួសរបស់លោកប៉ូល និងលោកស៊ីឡាសហើយ តើឆ្នាំគុក និងគ្រួសាររបស់គាត់ធ្វើអ្វី ?

តើព្រះយេស៊ូធ្វើដូចម្តេច ដើម្បីសង្គ្រោះយើង ?

តើនៅថ្ងៃទីបី (បន្ទាប់ពីគេឆ្កាងព្រះអង្គមក) ព្រះយេស៊ូធ្វើអ្វី ?

តើអ្នកជឿថា ការសុគតរបស់ព្រះយេស៊ូគ្រីស្តលួមគ្រប់គ្រាន់ ដើម្បីអោយព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់អ្នក និងគ្រួសាររបស់អ្នកដែរឬទេ ?

☐ លួមគ្រប់គ្រាន់ ។

☐ មិនលួមគ្រប់គ្រាន់ទេ ។

© Project WorldReach © SEAN

ហេតុអ្វីបានជាគេចាប់លោកប៉ូល និងលោកស៊ីឡាសទៅដាក់ក្នុងមន្ទីរឃុំឃាំង ?

តើលោកប៉ូល និងលោកស៊ីឡាសបានធ្វើអ្វីខ្លះ នៅពេលជាប់នៅក្នុងមន្ទីរឃុំឃាំង ?

ហេតុអ្វីបានជាច្រវាក់ដែលគេដាក់ពួកអ្នកទោស ត្រូវរបូតចេញ ?

តើឆ្នាំគុកប្រុងធ្វើអ្វីចំពោះខ្លួនគាត់ ?

ក្រោយដែលបានដោះលែងលោកប៉ូល និងលោកស៊ីឡាសពីគុក ហើយ តើឆ្នាំគុកសួរលោកប៉ូល និង លោកស៊ីឡាសថាដូចម្តេច ?

យើងបានសង្គ្រោះដោយសារជំនឿលើព្រះយេស៊ូគ្រីស្ត

ពេលនោះ ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ីបានកោះហៅក្រុមប្រឹក្សាជាន់ខ្ពស់មកប្រជុំ ហើយពោលថា÷ «អ្នកនោះបានធ្វើទីសំគាល់ជាច្រើន តើយើងគិតធ្វើដូចម្តេច ? ។ ប្រសិនបើយើងបណ្តោយអោយគាត់ធ្វើដូច្នេះតទៅទៀត ប្រជាជនមុខតែជឿទៅលើគាត់ទាំងអស់គ្នា ហើយជនជាតិរ៉ូម៉ាំងនឹងមកបំផ្លាញព្រះ-វិហារ និងបំបាត់ជាតិសាសន៍របស់យើងជាមិនខាន » ។

នៅក្នុងចំណោមពួកគេ មានលោកម្នាក់ឈ្មោះកៃផាស ដែលជាមហាបូជាចារ្យនៅឆ្នាំនោះ លោកមានប្រសាសន៍ទៅគេថា÷« អស់លោកពុំយល់អ្វីសោះ ! តើអស់លោកគិតមិនឃើញទេឬ ថាបើមនុស្សតែម្នាក់ស្លាប់ជាប្រយោជន៍ដល់ប្រជារាស្ត្រនោះ ប្រសើរជាងទុកអោយជាតិទាំងមូលត្រូវវិនាស !» ។

លោកមានប្រសាសន៍ដូច្នេះ មិនមែនផុសចេញពីគំនិតខ្លួនឯងផ្ទាល់ឡើយ គឺក្នុងឋានៈជាមហាបូជាចារ្យនៅឆ្នាំនោះ លោកបានទាយថា ព្រះយេស៊ូបានសោយទីវង្គត ដើម្បីជាប្រយោជន៍ដល់សាសន៍យូដា មិនគ្រាន់តែជាប្រយោជន៍ដល់សាសន៍នេះប៉ុណ្ណោះទេ គឺដើម្បីអោយកូនចៅរបស់ព្រះជាម្ចាស់ដែលបែកខ្ញែកគ្នា បានមករួបរួមជាប្រជាជនតែមួយទៀតផង ។

តាំងពីថ្ងៃនោះមក ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ី បានសំរេចធ្វើគុតព្រះយេស៊ូ (យ៉ូហាន ១១:៤៧-៥៣) ។

គេបណ្តើរព្រះយេស៊ូ នាំយកទៅដល់ដំណាក់របស់លោកមហាបូជាចារ្យ ។ ពួកនាយកបូជាចារ្យ ពួកព្រឹទ្ធាចារ្យ និងពួកបណ្ឌិតខាងវិន័យ មកជួបជុំទាំងអស់គ្នានៅទីនោះ ។ ព្រះយេស៊ូនៅស្ងៀមពុំឆ្លើយតបទាល់តែសោះ ។ លោកមហាបូជាចារ្យសួរព្រះអង្គម្តងទៀតថា÷ «តើអ្នកពិតជាព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះដែលយើងសរសើរតម្កើងមែនឬ ? » ។ ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា÷ *«មែន គឺខ្ញុំហ្នឹងហើយ ។ អស់លោកនឹងឃើញបុត្រមនុស្សគង់នៅខាងស្តាំព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមកជាមួយពពកនៅលើមេឃ !»* ។

លោកមហាបូជាចារ្យឮដូច្នេះ ក៏ហែកអាវរបស់លោក ហើយមានប្រសាសន៍ថា÷ «យើងមិនបាច់រកសាក្សីឯណាទៀតទេ អស់លោកឮជននេះពោលពាក្យប្រមាថព្រះជាម្ចាស់ស្រាប់ហើយ តើអស់លោកគិតដូចម្តេច ? » ។ គេបានសំរេចចិត្តទាំងអស់គ្នា កាត់ទោសប្រហារជីវិតព្រះយេស៊ូ ។ គេបណ្តើរព្រះយេស៊ូមកដល់កន្លែងមួយឈ្មោះ"កុលកូថា" ដែលប្រែថា"ភ្នំលលាដ៏ក្បាល" ។

ឆ្មាំគុកសុំអោយគេយកភ្លើងមក រួចប្រញាប់ប្រញាល់ចូលទៅក្នុងគុក ។ គាត់ក្រាបចុះនៅមុខលោកប៉ូល និងលោកស៊ីឡាសទាំងញាប់ញ័រ ។

គាត់នាំលោកទាំងពីរចេញមកក្រៅ ពោលថា÷ «លោកម្ចាស់ ! តើខ្ញុំប្របាទត្រូវធ្វើយ៉ាងណា ដើម្បីឱ្យបានទទួលការសង្គ្រោះ ?»។ លោកតបទៅគាត់វិញថា÷ «សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោក ព្រមទាំងសង្គ្រោះក្រុមគ្រួសាររបស់លោកផងដែរ » ។

បន្ទាប់មក លោកទាំងពីរបានប្រកាសព្រះបន្ទូលរបស់ព្រះអម្ចាស់ប្រាប់គាត់ និងប្រាប់អ្នកទាំងប៉ុន្មានដែលនៅក្នុងផ្ទះគាត់ ។ ពេលនោះឆ្មាំគុក នាំលោកទាំងពីរមកលាងស្នាមរបួសទាំងយប់ ហើយគាត់ និងក្រុមគ្រួសាររបស់គាត់ ក៏បានទទួលពិធីជ្រមុជទឹកភ្លាម ។ គាត់បាននាំលោកទាំងពីរឡើងទៅផ្ទះគាត់ រៀបចំម្ហូបអាហារជូន។ គាត់ និងក្រុមគ្រួសាររបស់គាត់មានអំណរសប្បាយ ដោយបានជឿលើព្រះជាម្ចាស់ ។ (កិច្ចការ ១៦:១៦-៣៤) ។

សាវ័កប៉ូលដេញខ្មោចចេញពីនារីបំរើនោះ ។ តើលោកប៉ូលដេញខ្មោចក្នុងនាមនរណា ?

© Project WorldReach © SEAN

បណ្ដាជនក៏លើកគ្នាមកប្រឆាំងនឹងលោកទាំងពីរដែរ ។ ពួកអាជ្ញាធរបានបញ្ជាអោយគេដោះសម្លៀកបំពាក់លោកប៉ូល និងលោកស៊ីឡាសចេញ រួចបញ្ជាអោយវាយនឹងរំពាត់ ។ ក្រោយពីបានវាយលោកទាំងពីរច្រើនរំពាត់ហើយ គេក៏យកលោកទៅដាក់ក្នុងទីឃុំឃាំង ទាំងបញ្ជាអោយយាមយ៉ាងមធ្យ័តផង ។ ឆ្នាំគុកក៏យកលោកទាំងពីរទៅឃុំក្នុងគុកងងឹត និងដាក់ខ្នោះជើងតាមបញ្ជាដែលគាត់បានទទួល ។

ប្រមាណជាពាក់កណ្ដាលអាធ្រាត្រ លោកប៉ូល និងលោកស៊ីឡាសនាំគ្នាអធិស្ឋាន និងច្រៀងសរសើរតម្កើងព្រះជាម្ចាស់ ។ អ្នកទោសឯទៀតៗស្ដាប់លោកទាំងពីរ ។ រំពេចនោះ ស្រាប់តែមានរញ្ជួយផែនដីយ៉ាងខ្លាំង បណ្ដាលឱ្យកក្រើកដល់គ្រឹះទីឃុំឃាំង ។

ទ្វារគុកទាំងប៉ុន្មាន ក៏របើកឡើងភ្លាម រីឯច្រវាក់ដែលគេដាក់អ្នកទោស ក៏របូតចេញអស់ដែរ ។ ពេលនោះ ឆ្នាំគុកភ្ញាក់ឡើង លុះគាត់ឃើញទ្វារគុករបើកដូច្នេះ គាត់ក៏ហូតដាវបំរុងនឹងសម្លាប់ខ្លួនព្រោះនឹកស្មានថា អ្នកទោសរត់បាត់អស់ហើយ ។ ប៉ុន្តែ លោកប៉ូលបានស្រែកឡើងយ៉ាងខ្លាំងៗថា÷ «កុំធ្វើបាបខ្លួនអី យើងទាំងអស់គ្នានៅឯនេះទេ ! » ។

គេយកស្រាទំពាំងបាយជូរលាយជាមួយគ្រឿងញៀនម្យ៉ាង មកថ្វាយព្រះអង្គសោយ ប៉ុន្តែ ព្រះអង្គពុំបានសោយទេ ។ គេក៏ឆ្កាងព្រះអង្គ ហើយយកសម្លៀកបំពាក់របស់ព្រះអង្គ មកចាប់ឆ្នោតចែកគ្នា ។

នៅពេលថៃត្រង់ ស្រាប់តែផែនដីទាំងមូលងងឹតសូន្យ រហូតដល់ម៉ោងបីរសៀល ។ នៅវេលាម៉ោងបីរសៀល ព្រះយេស៊ូស្រែកអង្វរខ្លាំងៗថា÷ *«អេឡយ អេឡយ ឡាម៉ាសាបាច់ថានី ?»* ពាក្យនេះប្រែថា *«ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ ? »* ។

ទ្រង់បន្ទឺព្រះសូរសៀងយ៉ាងខ្លាំងរួចរលត់វិញ្ញាណទៅ... ។ នាយទាហានរ៉ូម៉ាំង ដែលឈរនៅខាងមុខព្រះយេស៊ូឃើញព្រះអង្គរលត់វិញ្ញាណរបៀបនេះ ក៏ពោលឡើងថា÷ «បុរសនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន !» ។

លុះផុតថៃសប្ប័ទហើយ នាងម៉ារីជាអ្នកស្រុកម៉ាដាឡា នាងម៉ារីជាម្ដាយយ៉ាកុប និងនាងសាឡូមេ បានទិញគ្រឿងក្រអូបយកទៅអប់ព្រះសពព្រះយេស៊ូ ។ ព្រលឹមឡើងថៃអាទិត្យ នាងនាំគ្នាធ្វើដំណើរទៅកាន់ផ្នូរ នៅពេលថៃរះ ។ ពួកនាងនិយាយគ្នាថា÷«តើបាននរណាជួយរមៀលថ្មចេញពីមាត់ផ្នូរអោយយើង ?» ។

ពេលស្ត្រីទាំងនោះងើបមុខឡើង ក៏ឃើញថ្មបានរមៀលចេញរួចស្រេចទៅហើយ ថ្មនោះមានទំហំធំណាស់ ។ នាងចូលទៅក្នុងផ្នូរ ឃើញកំឡោះម្នាក់អង្គុយខាងស្តាំ មានសម្លៀកបំពាក់ពណិស ពួកនាងភ័យស្រឡាំងកាំង ។

អ្នកនោះពោលមកកាន់នាងថា÷ *«កុំភ័យស្រឡាំងកាំងធ្វើអ្វី ! នាងនាំគ្នាមករកព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត ដែលគេបានឆ្កាង ។ ព្រះជាម្ចាស់បានប្រោសព្រះអង្គ ឱ្យមានព្រះជន្មរស់ឡើងវិញហើយ ទ្រង់មិននៅទីនេះទេ មើលចុះទីនេះហើយ ដែលគេបានដាក់ព្រះសពព្រះអង្គ »* ។ (ម៉ាកុស ១៤:៥៣, ម៉ាកុស ១៤:៦១-៦៤, ម៉ាកុស ១៥:២២-២៤, ម៉ាកុស ១៥:៣៣-៣៩, ម៉ាកុស ១៦:១-៦) ។

ព្រះអម្ចាស់យាងមកគង់នៅកណ្តាលចំណោមសាវ័កទាំងអស់ ហើយមានព្រះបន្ទូលថា÷ *«សូមអោយអ្នករាល់គ្នា ប្រកបដោយសេចក្តីសុខសាន្ត»* ។ គេភ័យតក់ស្លុតញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានថាខ្មោចលង ។ ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តដូច្នេះ ? ម្តេចក៏អ្នករាល់គ្នានៅសង្ស័យ ? ចូរមើលដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន ! ចូរស្ទាបមើល៍ ខ្មោចគ្មានសាច់ គ្មានឆ្អឹងដូចខ្ញុំទេ »* ។

ព្រះអម្ចាស់យេស៊ូដែលមានព្រះជន្មរស់ឡើងវិញ សង្គ្រោះយើង ដោយសារជំនឿរបស់យើង

មានថ្ងៃមួយ ពេលយើងធ្វើដំណើរទៅកន្លែងអធិស្ឋាន មានស្រីបំរើគេម្នាក់មកជួបយើង នាងមានខ្មោចឈ្មោះពិថុនចូល នាំអោយនាងចេះទាយធ្វើឱ្យពួកម្ចាស់របស់នាងបានទទួលកំរៃយ៉ាងច្រើន ។ នាងដើរតាមក្រោយលោកប៉ូល និងយើងទាំងស្រែកថា÷ «លោកទាំងនេះ ជាអ្នកបំរើរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត លោកនាំដំណឹងអំពីមាគ៌ាមួយនៃការសង្គ្រោះមកប្រាប់អ្នករាល់គ្នា » ។

នាងធ្វើបែបនេះ អស់រយៈពេលជាច្រើនថ្ងៃ ។ ដោយលោកប៉ូលទាស់ចិត្តជាខ្លាំង ក៏ងាកទៅក្រោយបញ្ជាខ្មោចថា÷ «ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ចូរចេញពីនាងទៅ !» ខ្មោចក៏ចេញពីនាងភ្លាម ។

កាលពួកម្ចាស់របស់ស្រីបំរើនោះឃើញថាលែងមានសង្ឃឹមនឹងបានកំរៃអ្វីទៀត គេក៏នាំគ្នាចាប់លោកប៉ូល និងលោកស៊ីឡាសអូសយកទៅជូនចៅក្រមនៅលានសាធារណៈក្នុងទីក្រុង ។ ចៅក្រមនាំលោកទាំងពីរទៅជួបពួកអាជ្ញាធរ ពោលថា÷ «ជនជាតិយូដាទាំងនេះ បង្កអោយមានចលាចលនៅក្នុងក្រុងយើង ។ គេនាំទំនៀមទម្លាប់ផ្សេងៗមកផ្សាយប្រាប់យើង ជាទំនៀមទម្លាប់ ដែលយើងជនជាតិរ៉ូម៉ាំងគ្មានសិទ្ធិនឹងទទួល ឬ អនុវត្តតាមបានឡើយ » ។

អត្ថបទសិក្សា ទី ៥

"ដំណឹងល្អបំផុត"



ព្រះអង្គក៏បំភ្លឺចិត្តគំនិតគេអោយយល់អត្ថន័យគម្ពីរ ព្រះអង្គមានព្រះបន្ទូលថា÷ *«ហេតុការណ៍នេះ កើតឡើងស្របតាមសេចក្តីដែលចែងទុកក្នុងគម្ពីរមែន គឺព្រះគ្រីស្តត្រូវរងទុក្ខលំបាក ហើយមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។ អ្នករាល់គ្នាត្រូវប្រកាសក្នុងព្រះនាមព្រះអង្គ អោយមនុស្សគ្រប់ជាតិសាសន៍កែប្រែចិត្តគំនិត ដើម្បីអោយបានរួចពីបាប គឺត្រូវប្រកាសចាប់តាំងពីក្រុងយេរូសាឡឹមតទៅ»* ។ (លូកា ២៤:៣៦-៣៩, លូកា ២៤:៤៥-៤៧) ។

អ្នកណាកាត់ទោសព្រះអម្ចាស់យេស៊ូ ?

ហេតុអ្វីបានជាលោកមហាបូជាចារ្យខឹងនឹងព្រះយេស៊ូ ?

តើព្រះយេស៊ូធ្វើដូចម្តេច ដើម្បីសង្គ្រោះយើង ?

តើមានការអ្វីកើតឡើងនៅថ្ងៃទីបី ?

នៅក្រោយពេលមានព្រះជន្មរស់ឡើងវិញ តើព្រះអម្ចាស់ធ្វើអោយពួកសិស្សទ្រង់ជឿថា ទ្រង់មិនមែនជាខ្មោច ដោយរបៀបណា ?

«ព្រះគ្រីស្តបានផ្ទុកបាបរបស់យើងក្នុងព្រះកាយរបស់ព្រះអង្គ ដែលជាប់លើឈើឆ្កាង ដើម្បីអោយយើងលែងជំពាក់ជំពិននឹងបាបតទៅមុខទៀត ហើយឱ្យយើងមានជីវិត ដោយប្រព្រឹត្តតែអំពើសុចរិត ។ បងប្អូនបានជាសះស្បើយ ដោយសារស្នាមរបួសរបស់ព្រះអង្គ»។

(១ ពេត្រុស ២:២៤)

តើយញ្ញបូជាតែមួយគត់ ដែលនាំអោយព្រះជាម្ចាស់លើកលែងទោសបាបរបស់យើងជាអ្វី ?

តើអ្នក និងគ្រួសារអ្នកចង់អោយព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់អ្នក និងបានទទួលការសង្គ្រោះ ដោយសារការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់ដែរឬទេ ?

☐ ចង់ ។

☐ មិនចង់ទេ ។

ខ សំរាប់ទន្ទេញ

«ទីនេះមានទឹក តើមានអ្វីឃាត់ខ្ញុំ មិនឱ្យទទួលពិធីជ្រមុជទឹក !» ។

(កិច្ចការ ៨:៣៦)

កិច្ចការដែលត្រូវអនុវត្ត

- ពន្យល់ន័យអំពីពិធីជ្រមុជទឹកប្រាប់គ្រួសាររបស់អ្នក ។ (ពិធីជ្រមុជទឹកជាទីសំគាល់ថា ព្រះជាម្ចាស់លើកលែងទោសអំពើបាបអោយយើង ហើយយើងក៏បានរួមជាមួយព្រះគ្រីស្តដោយស្លាប់ខាងជីវិតពេញដោយអំពើបាប និងរស់ឡើងវិញដើម្បីចាប់ផ្តើមជីវិតថ្មី ជីវិតបរិសុទ្ធ និងជីវិតអស់កល្បដោយសារព្រះអង្គដែរ) ។
- និទានរឿងអំពីលោកភីលីព និង មន្ត្រីជាតិអេត្យូពី ប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

កូឡូស ២:១២ ចែងថា៖ *«ពេលបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយដោយបងប្អូនរួមក្នុងអង្គព្រះគ្រីស្ត បងប្អូនក៏មានជីវិតរស់ឡើងវិញ រួមជាមួយព្រះអង្គដែរ ព្រោះបងប្អូនមានជំនឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រីស្តអោយមានព្រះជន្មរស់ឡើងវិញ »* ។

ពិធីជ្រមុជទឹកមានពីរផ្នែក : ផ្នែកមើលឃើញដែលទាក់ទងនឹងរូបកាយ (ទឹក) និងផ្នែកខាងព្រលឹងវិញ្ញាណ (កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ) ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ធ្វើអោយយើងបានរួមជាមួយព្រះគ្រីស្ត ដោយសារជំនឿរបស់យើង ។

តើអ្នកណាដែលធ្វើអោយយើងបានរួមជាមួយព្រះយេស៊ូ ?
ព្រះ _____ ដ៏វិសុទ្ធ ។

តើអ្នកចង់អោយព្រះអង្គអត់ទោសអោយអ្នក ហើយអោយព្រះអង្គប្រទានជីវិតថ្មីដល់អ្នកដែរឬទេ ?

☐ ចង់ ។

☐ មិនចង់ទេ ។

ខ សំរាប់ទន្ទេញ

«ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឱ្យអស់អ្នក ដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ » ។

(យ៉ូហាន ៣:១៦)

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ លើកលែងទោសអំពើបាបរបស់អ្នក ដោយនូវព្រះនាមព្រះសង្គ្រោះតែមួយ គឺព្រះយេស៊ូគ្រីស្ត ។
- និយាយប្រាប់ក្រុមគ្រួសាររបស់អ្នកអំពីការកាត់ក្តី ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

អត្ថបទសិក្សា ទី ៣

"ជំណឹងល្អបំផុត"



តើអ្នកណាដែលផ្តល់ជីវិតដូចនេះដល់យើង ? _____

ពិធីជ្រមុជទឹកតំណាងការជំរះសំអាតយើងពីអំពើបាប ។ តែទឹក
មិនអាចជំរះអំពើបាបបានទេ ។ ១ យ៉ូហាន ១:៧ ចែងថា÷
*«លោហិតរបស់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះអង្គ ជំរះយើងឱ្យ
បានបរិសុទ្ធ រួចពីគ្រប់អំពើបាបទាំងអស់ »* ។

តើអ្វីដែលអាចជំរះសំអាតអំពើបាបរបស់យើងបាន ?

_____

ហេតុអ្វីបានជាពេលដែលយើងបានជឿលើព្រះគ្រីស្តហើយ ព្រះ-
ជាម្ចាស់មិនអោយយើងធ្លាក់ទៅស្ថាននរក ?

_____

_____

_____

_____

លោកបញ្ជាអោយគេបញ្ឈប់រទេះសេះ ។ លោកមន្ត្រី និងលោក ភីលីពចុះទៅក្នុងទឹកទាំងពីរនាក់ ហើយលោកភីលីពក៏ជ្រមុជទឹក ជូនមន្ត្រីនោះ ។ (កិច្ចការ ៨:២៧-៣៨) ។

នៅក្នុងវគ្គព្រះគម្ពីរ ដែលមន្ត្រីជាតិអេត្យូពីបានអាននេះ តើអ្នក ណាដែលត្រូវគេនាំយកទៅ ដូចជាចៀម ដែលគេនាំទៅសម្លាប់ ?

តើអ្នកណានាំអោយមន្ត្រីជាតិអេត្យូពីនោះជឿជាក់ថា ព្រះយេស៊ូជា ព្រះសង្គ្រោះ ?

តើមន្ត្រីជាតិអេត្យូពីនោះបង្ហាញថា គាត់ពិតជាជឿ ដោយរបៀប ណា ?

ពិធីជ្រមុជទឹកមានន័យថា យើងបានរួមជាមួយព្រះគ្រីស្ត ក្នុងការ សុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។ យើង ស្លាប់ លែងមានជីវិតពេញដោយអំពើបាប ហើយចាប់ផ្តើមជីវិត ថ្មី ដែលបរិសុទ្ធ និង អស់កល្ប ។

មនុស្សទាំងអស់សុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយចាំបាច់ត្រូវកែប្រែចិត្តគំនិត

មានអ្នកទារពន្ធ និងមនុស្សបាបទាំងអស់ នាំគ្នាចូលមកជិតព្រះ-យេស៊ូស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ។ ពួកខាងគណៈផារីស៊ី និងពួកបណ្ឌិតខាងវិន័យរអ៊ូរទាំថា៖« មើល ! អ្នកនេះរាក់ទាក់នឹង មនុស្សបាប ព្រមទាំងបរិភោគជាមួយគេផង !» ។

ព្រះយេស៊ូមានព្រះបន្ទូលទៅគេជាប្រស្នានេះថា៖ *«ក្នុងចំណោម អ្នករាល់គ្នា ឧបមាថាមានម្នាក់មានចៀមមួយរយក្បាល បើគាត់ បាត់ចៀមមួយ គាត់មុខជាទុកចៀមកៅសិបប្រាំបួនចោល នៅ ទីវាល ហើយទៅតាមរកចៀម ដែលបាត់នោះ រហូតទាល់តែបាន ឃើញវិញ »* ។

ខ្ញុំសុំប្រាប់អ្នករាល់គ្នាថា៖ *«ព្រះជាម្ចាស់នៅស្ថានបរមសុខ មាន អំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់កែប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការកែប្រែចិត្តគំនិត »* ។

ព្រះយេស៊ូមានព្រះបន្ទូលទៀតថា÷ «មានបុរសមួយរូប មានកូនប្រុសពីរនាក់ ។ កូនពៅនិយាយទៅឪពុកថា"លោកឪពុក ! សូមចែកកេរ្តិ៍មតិកអោយកូនមក ។ ឪពុកក៏ចែកមតិកអោយកូន ។

ប៉ុន្មានថ្ងៃក្រោយមក កូនពៅប្រមូលទ្រព្យសម្បត្តិ រួចចាកចេញទៅស្រុកឆ្ងាយ ។ នៅស្រុកនោះ កូនពៅបានខ្ជះខ្ជាយបង្ហិនទ្រព្យសម្បត្តិរបស់ខ្លួនអស់ទៅ ។ ពេលចាយវាយទ្រព្យសម្បត្តិអស់ហើយ ជួនជាកើតទុរ្ភិក្សយ៉ាងខ្លាំងនៅក្នុងស្រុក កូនពៅនោះចាប់ផ្តើមខ្វះខ្វាត ។ គាត់ក៏ទៅស៊ីឈ្នួលអ្នកស្រុកម្នាក់ ។ គេប្រើអោយគាត់មើលជ្រូកតាមស្រែចំការ ។ គាត់ចង់ចំអែតក្រពះនឹងចំណីដែលគេដាក់អោយជ្រូកស៊ីនោះណាស់ តែគ្មានអ្នកណាឱ្យបរិភោគឡើយ ។

ពេលនោះកូនពៅភ្ញាក់ខ្លួន ហើយរិះគិតក្នុងចិត្តថា អ្នកបំរើរបស់ឪពុកអញ សុទ្ធតែមានម្ហូបអាហារបរិភោគហូរហៀរទាំងអស់គ្នា រីឯនៅទីនេះវិញ អញសឹងតែដាច់ពោះស្លាប់ ។ អញត្រូវតែវិលត្រឡប់ទៅរកឪពុកអញវិញ ហើយជំរាបគាត់ថា÷"លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់

លោកក៏អញ្ជើញលោកភីលីពឡើងជិះរទេះសេះជាមួយ ។ រីឯអត្ថបទគម្ពីរ ដែលលោកកំពុងអាននោះ គឺ"*លោកត្រូវគេនាំយកទៅដូចជាចៀម ដែលគេនាំទៅសម្លាប់ លោកពុំបានហើបមាត់ទាល់តែសោះ គឺប្រៀបដូចជាកូនចៀម ដែលស្ងៀមស្ងាត់នៅមុខអ្នកកាត់រោម ។*

លោកត្រូវគេបន្ទាបបន្ថោក ហើយគេមិនរកយុត្តិធម៌ជូនលោកឡើយ ។ គ្មាននរណាអាចតំណាលអំពីពូជពង្សរបស់លោកបានទេ ព្រោះគេបានដកជីវិតរបស់លោកចេញពីផែនដីនេះបាត់ទៅហើយ"។ មន្ត្រីនោះសួរលោកភីលីពថា÷ «*សូមប្រាប់ខ្ញុំផង តើព្យាការីមានប្រសាសន៍ដូច្នេះ សំដៅលើអ្នកណា ? តើលោកមានប្រសាសន៍អំពីខ្លួនលោកផ្ទាល់ ឬមានប្រសាសន៍អំពីអ្នកណាម្នាក់ផ្សេងៗទៀត ?* » ។

លោកភីលីពក៏ជំរាបជូនដំណឹងល្អ អំពីព្រះយេស៊ូប្រាប់លោកដោយចាប់ផ្តើមពីអត្ថបទគម្ពីរនោះទៅ ។ លោកទាំងពីរចេះតែបន្តដំណើរទៅមុខ ។ លុះដល់កន្លែងមួយមានទឹក លោកមន្ត្រីមានប្រសាសន៍ថា÷ «ទីនេះមានទឹក តើមានអ្វីឃាត់ខ្ញុំមិនអោយទទួលពិធីជ្រមុជទឹក ! » ។

© Project WorldReach © SEAN

ពិធីជ្រមុជទឹកតំណាងការស្លាប់ និងការកប់ទៅក្នុងផ្នូររបស់យើងជាមួយព្រះគ្រីស្ត

ទេវទូតរបស់ព្រះអម្ចាស់ពោលមកកាន់លោកភីលីពថា÷ *«សូមក្រោកឡើងធ្វើដំណើរតាមផ្លូវចុះពីក្រុងយេរូសាឡឹម ទៅក្រុងកាសាជាផ្លូវស្ងាត់នោះទៅ»* ។ លោកភីលីពក៏ក្រោកឡើងចេញដំណើរទៅ ។ នៅតាមផ្លូវមានជនជាតិអេត្យូពីមួយរូប ជាមនុស្សកម្រៀវលោកជាមន្ត្រីជាន់ខ្ពស់របស់មហាក្សត្រីយានីកន់ដាស ដែលគ្រងរាជ្យនៅស្រុកអេត្យូពី ហើយលោកជាអ្នកកាន់កាប់ព្រះរាជទ្រព្យទាំងប៉ុន្មាន ។ លោកបានមកថ្វាយបង្គំព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម ហើយធ្វើដំណើរវិលត្រឡប់ទៅវិញ ដោយជិះរទេះសេះទាំងអានគម្ពីរព្យាការីអេសាយផង ។

ព្រះវិញ្ញាណមានព្រះបន្ទូលមកលោកភីលីពថា÷ *«ចូរទៅមុខ រួចចូលទៅជិតរទេះសេះនោះទៅ»* ។ លោកភីលីពក៏រត់ទៅមុខ ហើយឮមន្ត្រីអេធីព្យូពីអានគម្ពីរព្យាការីអេសាយ លោកភីលីពសួរមន្ត្រីនោះថា÷ «តើលោកយល់សេចក្ដី ដែលលោកកំពុងតែអាននេះឬទេ ? »។

លោកមន្ត្រីតបមកវិញថា÷ «ធ្វើម្ដេចអោយខ្ញុំយល់បាន បើគ្មាននរណាពន្យល់ណែនាំសោះនោះ ! » ។

កូនក៏បានប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ ។ មិនគួរអោយលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ ។ សូមលោកឪពុកចាត់ទុកកូនជាអ្នកបំរើចុះ" ។ លុះគិតដូច្នោះហើយ កូនពៅក៏វិលត្រឡប់ទៅរកឪពុកវិញ ។

កាលឪពុកឃើញកូនពីចំងាយ ។ គាត់មានចិត្តអាណិតអាសូរក្រៃលែង ក៏រត់ទៅទទួលកូន ហើយឱបថើបទៀតផង ។ កូនពៅជំរាបឪពុកថា÷ "លោកឪពុក កូនបានប្រព្រឹត្តអំពើបាបខុសនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូនក៏ប្រព្រឹត្តអំពើបាបខុសនឹងលោកឪពុកដែរ ។ មិនគួរអោយលោកឪពុករាប់ខ្ញុំនេះជាកូនទៀតទេ" ។

ឪពុកប្រាប់ពួកអ្នកបំរើថា÷"ចូរទៅយកសម្លៀកបំពាក់ល្អៗបំផុតមកពាក់អោយកូនខ្ញុំជាប្រញាប់ ហើយយកចិញ្ចៀន និងស្បែកជើងមកពាក់អោយផង ។ ចូរយកកូនគោដែលយើងបានបំប៉នទុក មកកាប់ជប់លៀងអោយសប្បាយចុះ ដ្បិតកូនខ្ញុំនេះ បានស្លាប់ទៅហើយ តែឥឡូវរស់ឡើងវិញ វាវង្វេងបាត់ តែឥឡូវនេះ ខ្ញុំរកឃើញវិញហើយ" ។ គេនាំគ្នាជប់លៀងយ៉ាងសប្បាយ ។

អត្ថបទសិក្សា ទី ៤

"ជំណឹងល្អបំផុត"



កូនច្បងខឹងណាស់ មិនព្រមចូលផ្ទះទេ ឪពុកចេញមកអង្វរអោយចូល ។ កូនច្បងនិយាយទៅកាន់ឪពុកថា÷ "ខ្ញុំបាននៅបំរើលោកជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដែលធ្វើខុសនឹងបង្គាប់របស់លោកត្រង់ណាឡើយ តែលោកមិនដែលអោយកូនពពែ ដើម្បីអោយខ្ញុំកាប់ជប់លៀងជាមួយមិត្តភក្តិទាល់តែសោះ សូម្បីតែមួយ ក៏មិនដែលផង ។ ពេលកូនលោកត្រឡប់មកវិញ លោកបានកាប់កូនគោបំប៉នទទួលវា ។ មើល៎វានេះ បានបំផ្លាញទ្រព្យសម្បត្តិលោកទាំងអស់ជាមួយស្រីពេ្យ" ។

ឪពុកនិយាយទៅកូនថា÷ "កូនអើយ ឯងនៅជាមួយឪពុកជានិច្ច រហូតណាកូន អ្វីៗទាំងអស់ដែលជារបស់ឪពុក ក៏ជារបស់កូនដែរ ។ យើងត្រូវតែសប្បាយរីករាយ ដ្បិតប្អូនរបស់ឯងដែលបានស្លាប់ទៅនោះ ឥឡូវនេះរស់ឡើងវិញហើយ ។ វាបានវង្វេងបាត់តែឥឡូវនេះ យើងរកឃើញវិញហើយ" » ។ (លូកា ១៥:១-៤, លូកា ១៥:៧, លូកា ១៥:១១-២៤, លូកា ១៥:២៨-៣២) ។

តើកូនពៅធ្វើខុសអ្វី ?

សូមគូសសញ្ញា «✓» នៅក្នុងប្រអប់ «□» ត្រង់ចំលើយដែលត្រឹមត្រូវ ។

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់បំពេញអ្នក ដោយព្រះ-វិញ្ញាណព្រះអង្គ ដើម្បីកែប្រែជីវិតអ្នក និងធ្វើឱ្យចិត្តគំនិតអ្នកក្លាយជាថ្មី ។
- និយាយរឿងអំពីកូនពៅដែលវង្វេងច្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

តើបន្ទាប់មក វាដឹងកំហុសរបស់ខ្លួនដែរឬទេ ?

☐ ដឹង ។

☐ មិនដឹងទេ ។

កូនប្រុសពៅនោះបានកែប្រែចិត្តគំនិតពីអំពើបាប ។ តើអ្នកគិតថាមនុស្សទាំងអស់មានបាបដែរឬទេ ?

☐ មាន ។

☐ មិនមានទេ ។

កូនពៅតំណាងមនុស្សមានបាប ដែលបានកែប្រែចិត្តគំនិតដោយស្មោះ ។ តើឪពុកតំណាងនរណា ?

_____

ឪពុកតំណាងព្រះជាម្ចាស់ ។ តើឪពុករបស់គាត់លើកលែងទោសអោយគាត់ដែរឬទេ ?

☐ លើកលែង ។

☐ មិនលើកលែងទេ ។

បើសិនជាអ្នកពិតជាកែប្រែចិត្តគំនិតមែន តើព្រះបិតារបស់អ្នក ដែលគង់នៅស្ថានបរមសុខ នឹងលើកលែងទោសអោយអ្នក ដែរឬទេ ?

☐ លើកលែង ។

☐ មិនលើកលែងទេ ។

ក្នុងចំណោមតំណាងមនុស្សដែលប្រកាន់សាសនា ដែលមើលស្រាល ចំពោះពួកអ្នកជឿថ្មី ។ ពួកអ្នកទាំងនេះគិតថា មានតែពួកគេទេ ដែលអាចទទួលព្រះគុណសន្តោសរបស់ព្រះជាម្ចាស់បាន ។ ប៉ុន្តែ ព្រះយេស៊ូមានបន្ទូលថា នឹងមានអំណរនៅក្នុងស្ថានបរមសុខ បើ សិនជាមានមនុស្សបាបម្នាក់កែប្រែចិត្តគំនិត ។

តើព្រះជាម្ចាស់នឹងសប្បាយព្រះទ័យ ដោយសារអ្នកនៅពេល ណា ? _____

ដើម្បីសង្គ្រោះយើង តើព្រះអម្ចាស់យេស៊ូធ្វើដូចម្តេច ?

_____

_____

នៅពេលដែលយើងទទួលព្រះយេស៊ូគ្រីស្ត ដោយជំនឿនោះ ព្រះ-វិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ នឹងយាងមកគង់ក្នុងចិត្តយើង ។ ព្រះអង្គនឹងជួយយើងឱ្យកែប្រែចិត្តគំនិត ។ តើអ្នកត្រូវការកែប្រែ ជាប្រចាំដូចនេះ ក្នុងជីវិតអ្នកដែរឬទេ ?

☐ ត្រូវការ ។

☐ មិនត្រូវការទេ ។

ស្របទៅតាមព្រះគម្ពីរ ជំនឿដែលមិនបង្កើតផលផ្លែ ជាជំនឿ ដែលគ្មានប្រយោជន៍ទាល់តែសោះ ។ តើនរណាជួយយើងអោយ អាចកែប្រែយ៉ាងខ្លាំងដូចនេះបាន ?

ព្រះវិញ្ញាណនៃ _____ ។

ខ សំរាប់ទន្ទេញ

«សូមបងប្អូនកែប្រែចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជ ទឹកក្នុងព្រះនាមព្រះយេស៊ូគ្រីស្តទៅ ដើម្បីព្រះជាម្ចាស់លើកលែង ទោសបងប្អូនអោយរួចពីបាប ហើយបងប្អូននឹងទទួលព្រះវិញ្ញាណ ដ៏វិសុទ្ធ ដែលជាអំណោយទានរបស់ព្រះជាម្ចាស់ » ។

(កិច្ចការ ២:៣៨)

© Project WorldReach © SEAN